ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ ១១៤/២២ គ.ជ.ប.ជ

# របាយការណ៍ត្រីមាសទី១
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅអនុវត្តបន្តត្រីមាសទី២ ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះប្រទេសជាតិ បាន និងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តន៍ថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងការជះឥទ្ធិពលពីការប្រែប្រួលនៃសភាពការណ៍ពិភពលោក ដែលមានទាំងវិបត្តិសេដ្ឋកិច្ច សង្គ្រាមរ៉ាំរ៉ៃនៅ បណ្តាប្រទេសមួយចំនួន គ្រោះធម្មជាតិ( ទឹកជំនន់ ខ្យល់ព្យុះ ខ្យល់កន្ត្រាក់ បំណាក់ដី ភ្លើងឆេះព្រៃ...) និងថែមទាំងគ្រោះមហន្តរាយដោយការរាតត្បាតដោយវីរុសកូវីដ ១៩ និងមេរោគបម្លែងថ្មី។

រាជរដ្ឋាភិបាលបាន និងកំពុងតែ យកចិត្តទុកដាក់យ៉ាងខ្លាំង លើកិច្ចការពារអាយុជីវិតប្រជាពលរដ្ឋដែលបង្កដោយការរាតត្បាតដ៏ខ្លាំងក្លានៃវីរុសកូវីដ ១៩ និងផលប៉ះពាល់ដ៏ធំធេងលើ ជីវភាព និងសុខភាពប្រជាពលរដ្ឋ ព្រមទាំងសេដ្ឋកិច្ចសង្គមយ៉ាងធ្ងន់ធ្ងរ ជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ នូវផែនការសកម្មភាពនានា ដែលបានគ្រោងទុក និងត្រូវបន្ថែមភារកិច្ចក្នុងការដោះស្រាយ ទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ចំណែកឯប្រជាជនយើង មួយចំនួននៅតែមើលស្រាលស្ថានភាព មិនស្តាប់ការអប់រំណែនាំ មិនតាមដានព័ត៌មានដែលមានប្រយោជន៍ តែបែរជាស្តាប់ និងជឿការអូសទាញ ភូតភរពីមេខ្យល់ ធ្វើឲ្យពួកគាត់ធ្លាក់ទៅក្នុងអំពើជួញដូរមនុស្ស និងខាតបង់ដទៃធ្ងន់ធ្ងរ។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាព ជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

រាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- **ក្រសួងយុត្តិធម៌** បានរៀបចំ៖
  - បន្តពិនិត្យសេចក្តីព្រាងច្បាប់ ស្តីពី «ការប្រឆាំងអំពើរត់ពន្ធមនុស្ស» និងច្បាប់ស្តីពី «អំពើពពោះជំនួស»។
  - សេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសប៊ែលហ្សិក ប៉េរូ និងប្រទេសឡាវ ស្តីពី «ការបញ្ជូនទណ្ឌិត»។
  - សន្ធិសញ្ញា ស្តីពី បត្យាប័ន ជាមួយប្រទេសឥណ្ឌា និងប្រទេសបេឡារុស។
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាន និងកំពុងសិក្សារៀបចំសេចក្តីព្រាងច្បាប់ ស្តីពី «ទេសន្តរប្រវេសន៍ការងារកម្ពុជានៅបរទេស»។

#### ក.២. សន្ធិសញ្ញា

- **ក្រសួងយុត្តិធម៌**
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "**ការបញ្ជូនទណ្ឌិត**"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- **គណៈកម្មាការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចុះអនុស្សរណៈនៃការយោគយល់គ្នា ចំនួន ០៣ គឺជាមួយ៖
  - អង្គការការីតាស្វីស ស្តីពី «ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរាល់ទម្រង់នៃការកេងប្រវ័ញ្ចក្នុងការធ្វើចំណាកស្រុក ឆ្នាំ២០២២-២០២៤»។
  - **អង្គការ Erikshjalpen** ស្តីពីសកម្មភាពបង្ការ ទប់ស្កាត់ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២)។
  - **អង្គការ វីនរ៉ក់អន្តរជាតិ** ដើម្បីរួមចំណែកលើកកម្ពស់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបង្កើនប្រសិទ្ធភាពវិធានការប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២)។
- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ បានរៀបចំកិច្ចប្រជុំពិនិត្យលើសេចក្តីព្រាងប្រកាស ស្តីពីលក្ខខណ្ឌការងារកុមារ ក្នុងមុខរបរផលិតកម្មអំពៅចំនួន ០៣លើក នៅថ្ងៃទី៧ និងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២ និងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។
- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។
- **ក្រសួងកិច្ចការនារី** បានរៀបចំ៖

-សេចក្តីព្រាងវិសោធនកម្មអនុស្សរណៈនៃការយោគយល់ ស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងការជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ(COMMIT)។

-សេចក្តីព្រាងយន្តការបញ្ជូនឆ្លងដែនមានលក្ខណៈស្តង់ដារួមគ្នាតែមួយ និងរួមទាំងចាត់តាំងគ្រូបង្គោលរបស់ប្រទេសជាសមាជិកខមមីត(COMMIT)នីមួយៗ។

**ក.៤. កិច្ចសហប្រតិបត្តិការអន្តរជាតិ**

- **គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានរៀបចំកិច្ចប្រជុំ៖

-ជាមួយសមាជិកគណៈកម្មាធិការ និងមន្ត្រីជំនាញពីតាមបណ្តាក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការដៃគូជាតិ និងអន្តរជាតិ ស្តីពី «ការពិនិត្យឡើងវិញនូវ លទ្ធផលការងារ ភាពប្រឈម» (២០១៩-២០២១) និងគំនិតផ្តួចផ្តើមសម្រាប់ការអនុវត្តផែនការយុទ្ធសាស្ត្របន្ត(២០២២-២០២៣) តាមប្រព័ន្ធអនឡាញ។

-ជាច្រើនលើក តាមប្រព័ន្ធអនឡាញ ជាមួយអង្គការសហប្រជាជាតិទទួលបន្ទុកការងារទេសន្តរប្រវេសន៍នៅទីក្រុងហ្សឺណែវ បណ្តាញអង្គការទេសន្តរប្រវេសន៍របស់អង្គការសហប្រជាជាតិប្រចាំតំបន់ អគ្គលេខាធិការដ្ឋានអាស៊ាន និងជាមួយអន្តរក្រសួង ស្ថាប័ន ក្នុងការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងនាមជាប្រទេសជ័យលាភីក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់។

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖

-បំពេញបេសកកម្មនៅប្រទេសថៃ ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ដើម្បីតម្លើងសម្ភារ និងប្រព័ន្ធតភ្ជាប់ ជូនស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំព្រះរាជាណាចក្រថៃឡង់ដ៍ សម្រាប់មន្ត្រីស្ថានទូតប្រើប្រាស់ និងដាក់ឱ្យដំណើរការនូវប្រព័ន្ធបន្តសុពលភាពបណ្ណ OCWC និងលិខិតធ្វើដំណើរ TD ។

-ដឹកនាំកិច្ចប្រជុំរបស់ក្រុមការងារស្នូលកម្ពុជានៃក្រុមការងារមហាអនុតំបន់មេគង្គស្តីពីទេសន្តរប្រវេសន៍ការងារ (GMS Task Force on Labour Migration) ជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ ដើម្បីត្រៀមរៀបចំវេទិកា ស្តីពីទេសន្តរប្រវេសន៍ការងារសម្រាប់បណ្តាប្រទេសក្នុងតំបន់ GMS។

## ខ. ការបង្ការ ទប់ស្កាត់

### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

#### ខ.១.១ .ការផ្សព្វផ្សាយដោយផ្ទាល់

| ការផ្សព្វផ្សាយដោយផ្ទាល់ | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|
| កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ | ២៧.៨២៥ | ១.១៨៥.១៣០ | ៦០៧.០៨៧ |
| តាមរយៈកម្មវិធីផ្សេងៗ ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ | ៦៦ | ២.៧៩២ | ១.៦៦៩ |
| អង្គការដៃគូ | ០៧ | ១.៤០៧ | ៨៦៤៥ |
| សរុប | ២៧.៨៩៨លើក | ១.១៨៩.៣២៩នាក់ | ៦១៧.៤០១នាក់ |

ខ.១.១.១. កិច្ចប្រជុំ និងវេទិកាផ្សព្វផ្សាយជាសាធារណៈ

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាក

ស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **២៧.៨២៥**លើក មានអ្នកចូលរួមសរុបចំនួន **១.១៨៥.១៣០**នាក់ (ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២១ មានចំនួន **១.៧០១.៦៤៦**នាក់ គឺមានការថយចុះចំនួន **៥១៦.៥១៦**នាក់ ស្មើនឹង **៣០,៣៥%** ក្នុងនោះស្ត្រីចំនួន **៦០៧.០៨៧**នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ: ចំនួន ដង/លើក | ផ្សព្វផ្សាយ: ចំនួន មនុស្ស | ផ្សព្វផ្សាយ: ចំនួន ស្ត្រី | វេទិកាសាធារណៈ: ចំនួន ដង/លើក | វេទិកាសាធារណៈ: ចំនួន មនុស្ស | វេទិកាសាធារណៈ: ចំនួន ស្ត្រី |
|---|---|---|---|---|---|---|---|
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៦០ | ១០.៤១៣ | ៥.៤៩២ | ៥៤ | ២.២៤៩ | ១.១៩៥ |
| | សរុប ក្រសួង ស្ថាប័ន | ១៦០ លើក | ១០.៤១៣ នាក់ | ៥.៤៩២ នាក់ | ៥៤នាក់ | ២.២៤៩នាក់ | ១.១៩៥នាក់ |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ២.២១៨ | ៩២.៤៨២ | ៥២.៨៥២ | ២.៩៤០ | ១៦១.០៨៦ | ៨២.៦៤២ |
| ៣ | ខេត្តបាត់ដំបង | ១.៦២៣ | ៦៩.៣៥៩ | ២៦.៦៣២ | ១.០០០ | ២៧.៤០៤ | ១៤.៥៤២ |
| ៤ | ខេត្តពោធិ៍សាត់ | ១.៣៧៦ | ១១៥.៧០៤ | ៦៥.៨៨៤ | ៣៧៤ | ១២.៦៥៥ | ៦.២១១ |
| ៥ | ខេត្តសៀមរាប | ២៨៤ | ១៤.០៩៦ | ៧.២៨៨ | | | |
| ៦ | ខេត្តកំពង់ឆ្នាំង | ៣.២១៦ | ៧៦.៤០៥ | ៣៨.១៨៦ | ១.៧៥៨ | ៣១.២៩៣ | ១៧.៤៦៥ |
| ៧ | ខេត្តកំពង់ចាម | ៥.៩៦២ | ៣៤១.០៨៨ | ១៧៨.៥៦០ | ៣.៤៤៣ | ១០២.៦៤២ | ៤៩.៥៧៥ |
| ៨ | ខេត្តព្រះសីហនុ | ៧ | ៣៦៤ | ២០៥ | | | |
| ៩ | ខេត្តព្រះវិហារ | ៤៦ | ៤.៦៨៤ | ៣.១៨៩ | ១២ | ៥២៨ | ៣២៤ |
| ១០ | ខេត្តស្វាយរៀង | | | | ៨២៧ | ២៤.១០៤ | ១៣.១៨៣ |
| ១១ | ខេត្តប៉ៃលិន | ៣៤៣ | ៧.៣៣៦ | ២.២៦៨ | ១៧៥ | ៧.៣៣៧ | ២.៣២៥ |
| ១២ | ខេត្តកោះកុង | ៣៥ | ៦៥៧ | ៣១៧ | ១១៣ | ២.២៩០ | ១.១៧៨ |
| ១៣ | ខេត្តកំពត | ៧៧ | ១.៨០៧ | ៩៦៦ | ៣០ | ១.០៦៩ | ៦៧៣ |
| ១៤ | ខេត្តកំពង់ធំ | ៨៨ | ៦.២០១ | ៤៤០៩ | | | |
| ១៥ | ខេត្តតាកែវ | ៧៩៦ | ២៤.២៨២ | ១១.៥១៤ | ២៦៧ | ៨.៨៤១ | ៤.០៧៩ |
| ១៦ | ខេត្តក្រចេះ | ៤៧ | ២.០៩៦ | ៩៨១ | | | |
| ១៧ | ខេត្តកែប | ៤២ | ៦.៦៣៩ | ២.០១៧ | ៥៥ | ២.៤៦៥ | ១.០៨២ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | ១៧ | ១.០៥០ | ២៧៦ | | | |
| ២១ | ខេត្តព្រៃវែង | ៣១៦ | ១៨.០៧៩ | ៨.៨២៦ | ១៣ | ២.១០៣ | ៣៣៧ |
| ២២ | ខេត្តត្បូងឃ្មុំ | ០៨ | ២.៧០៩ | ១.៣៦៩ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១៨ | ១.៩៥៦ | ៣២៥ | ០៣ | ៤១២ | ២១៣ |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | ៨២ | ១.២៤៥ | ៥០៧ | | | |
| | សរុប រាជធានី-ខេត្ត | ១៦.៦០១ | ៧៨៨.២៣៩ | ៤០៦.៥៧១ | ១១.០១០ | ៣៨៤.២២៩ | ១៩៣.៨២៩ |
| | សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន ២៧.៨២៥ លើក | | ចំនួនមនុស្សសរុប ១.១៨៥.១៣០ នាក់ | | ចំនួនស្ត្រី ៦០៧.០៨៧ នាក់ | |

២.១.១.២. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- ថ្នាក់ជាតិ
  - **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានសហការជាមួយ **ក្រសួងអប់រំ យុវជន និងកីឡា** អង្គការ Aple Cambodia និងសហការ ឧបត្ថម្ភដោយអង្គការ Plan International Cambodia អង្គការ UNICEF និងក្រុមហ៊ុន Smart Axiata រៀបចំយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត **"រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារតាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ"** ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្នកចូលរួមប្រមាណ **៣៥០**នាក់ នៅវិទ្យាស្ថានជាតិអប់រំ និងបានបន្តផ្សព្វផ្សាយ តាមប្រព័ន្ធអនឡាញ ដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស បានប្រមាណ **២៥០**នាក់បន្ថែមទៀត។
  - **អង្គការដៃគូ**
    - **អង្គការតំណក់ទឹក៖** បានសហការជាមួយអាជ្ញាធរភូមិ/ឃុំ/សង្កាត់ ខេត្តបន្ទាយមានជ័យ៖
      -ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ ដើម្បីលើកកម្ពស់នៅក្នុងសហគមហ៍ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋនៅក្នុងភូមិ/ឃុំ/សង្កាត់ បានចំនួន ០១លើក មានអ្នកចូលរួមចំនួន ៤១១នាក់(ស្រី ២២៨នាក់។

      -ផ្សព្វផ្សាយតាមរយៈការចុះធ្វើបណ្ណាល័យចល័ត ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងផ្សព្វផ្សាយពីសេវារបស់អង្គការតំណក់ទឹកនៅតាមសហគមន៍ នៅសង្កាត់ប៉ោយប៉ែត ផ្សារកណ្តាល និងសង្កាត់និមិត្ត បានចំនួន ០២លើក មានអ្នកចូលរួមចំនួន ៥២៦នាក់(ស្រី ២៤៨នាក់។

      **-អង្គការទេសន្តរប្រវេសន៍ IOM៖** បានសហការជាមួយរដ្ឋបាលស្រុកពួក និងស្រុកស្វាយលើ ខេត្តសៀមរាប ធ្វើការផ្សព្វផ្សាយអំពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការផ្តល់ការងារជូនពលករចំណាកស្រុក នៅឃុំពួក និងឃុំសំរោងយា ស្រុកពួក និងឃុំស្វាយលើ ស្រុកស្វាយលើ បានចំនួន ០៣លើក មានអ្នកចូលរួមចំនួន ៤២៥នាក់(ស្រី ១៦៨នាក់។

      **-អង្គការបន្ទាយស្រី៖** បានសហការជាមួយរដ្ឋបាលស្រុកអង្គរជុំ ខេត្តសៀមរាប បានរៀបចំកិច្ចប្រជុំជាមួយក្រុមបុរស នៅឃុំដូនពេង គោកដូង គោល នគរភាស ស្រែខ្វាវ និងឃុំតាសោម ស្តីពី កិច្ចការពារកុមារ ដែលចំណាកស្រុកតាមឪពុកម្តាយឱ្យមានសុវត្ថិភាព ដើម្បីគាំទ្រដល់ស្ត្រី និងក្មេងស្រី ០១លើក មានអ្នកចូលរួមចំនួន ៤៥នាក់(ស្រី ០១នាក់។

- **ថ្នាក់ក្រោមជាតិ**
  - **ខេត្តកំពង់ចាម៖**
    - **រដ្ឋបាលក្រុង ស្រុកទាំង១០៖**បានអប់រំផ្សព្វផ្សាយទៅតាមរយៈការប្រជុំ គ.ស.ន.ក និងគ.ក.ន.ក ពាក់ព័ន្ធទៅនឹងការចាប់រំលោភសេពសន្ថវៈទៅលើស្ត្រី និង កុមារ និងអំពីបញ្ហាចំណាកស្រុកទៅរកការងារធ្វើ ចៀសវាងការឆបោកតាមរយៈមេខ្យល់។
    - **មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាន៖** ១-សហការជាមួយក្រុមការងារប្រឆាំងអំពើជួញដូរមនុស្សស្រុកជើងព្រៃ ចុះផ្សព្វផ្សាយការបង្ការ និងទប់ស្កាត់អំពើជួញដូរមនុស្ស ដល់យុវជនទាំង១០ក្រុង ស្រុក ដែលបានមកចូលរួមការបោះជំរំយុវជនថ្នាក់ខេត្ត នៅវិទ្យាល័យ ហ៊ុន សែន ស្គន់ ចំនួន **១៥០**នាក់។ ២-ផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន និងការប្រជុំក្រុមឪពុកម្តាយកុមារតូចអាយុ០ដល់៣ឆ្នាំ តាមភូមិគោលដៅក្នុងឃុំ និងក្រុង-ស្រុក។ និងបានផ្សព្វផ្សាយដល់សហគមន៍ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យ

តាមដាន ដល់សិស្សដែលរៀនថ្នាក់អក្ខរកម្មវិជ្ជាជីវៈ ថ្នាក់សមមូលបឋមសិក្សា និងថ្នាក់មជ្ឈមណ្ឌលសិក្សា សហគមន៍ តាមភូមិ ឃុំ និងក្រុង-ស្រុក ដែលបានអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ។

- **ខេត្តកណ្ដាល** អនុវត្តតាមផែនការសកម្មភាពបង្ការទប់ស្កាត់ការជួញដូរមនុស្ស របស់ គ.ខ.ប.ជ ខេត្តៈ
    - មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានបញ្ជ្រាបការផ្សព្វផ្សាយអំពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈការប្រជុំបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡាប្រចាំខែធ្នូ ឆ្នាំ២០២១ និងត្រៀមរៀបចំបើកបវេសមកាល ឆ្នាំសិក្សាថ្មី នៅសាលប្រជុំមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដែលមានការចូលរួមពី ថ្នាក់ដឹកនាំមន្ទីរ លោកប្រធានការិយាល័យចំណុះមន្ទីរ ប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាល ក្រុង/ស្រុកទាំង១១ លោកស្រីនាយិកាវិទ្យាល័យទូទាំងខេត្ត សរុបចំនួន **៦៧**នាក់(ស្រី **០៣**នាក់)។
    - លេខាធិការដ្ឋានគ.ខ.ប.ជ បានបញ្ជ្រាបការផ្សព្វផ្សាយអំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងកិច្ចប្រជុំរៀបចំពិធីអបអរសាទរខួបលើកទី១១១ ទិវានារីអន្តរជាតិ ៨មីនា ឆ្នាំ២០២២ ក្រោមប្រធានបទ សមភាពយេឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត មានអ្នកចូលរួមសរុប **៥៤**នាក់។
- **ខេត្តបន្ទាយមានជ័យៈ** បានបញ្ជ្រាបការផ្សព្វផ្សាយអប់រំ អំពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈលោកស្រី **រស់ សុផានី** រួមសហការជាមួយមន្ទីរសង្គមកិច្ច បានចុះសួរសុខទុក្ខ រួមនឹងចែកអំណោយដល់ស្ត្រីមានផ្ទៃពោះ និងកុមារនៅមណ្ឌលចត្តាឡីស័កកងវ៉ាំ ចំនួន **៣១**នាក់។
- **ខេត្តតាកែវៈ** បានបើកវេទិកាថ្នាក់ដឹកនាំ និងកុមារប្រចាំឆ្នាំ២០២២ ក្រោមប្រធានបទផ្សព្វផ្សាយ និងការអនុវត្តច្បាប់លិខិតបទដ្ឋានគតិយុត្តិ ឆ្លើយតបនឹងកិច្ចការពារកុមារ ចំនួន ០១លើក មានអ្នកចូលរួមចំនួន **៩៥**នាក់(ស្រី **៧៥**នាក់)។
- **ខេត្តបាត់ដំបងៈ** លេខាធិការដ្ឋាន គ.ខ.ប.ជ តាមរយៈនិងវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ បានបញ្ជ្រាបកាផ្សព្វផ្សាយច្បាប់ ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ឱកាសស្វែងរកការងាររបស់ប្រជាពលរដ្ឋ និងវិធានការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅមណ្ឌលទទួលពលករ កំរៀង ស្ថិតនៅស្រុកកំរៀង។
- **ខេត្តកំពតៈ** បានផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំគ.ក.ស.ក និងកិច្ចប្រជុំ គ.ក.ន.ក សរុប **២៧**លើក អ្នកចូលរួមសរុប **២៨៩**នាក់ ស្រី **២៧៩**នាក់។
- **ខេត្តសៀមរាប** រដ្ឋបាលស្រុកពួកៈបានរៀបចំយុទ្ធនាការផ្សព្វផ្សាយការប្រើប្រាស់សេវាការងារ តាមប្រព័ន្ធអ៊ីនធឺណិត និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ នៃការធ្វើចំណាកស្រុកដោយស្របច្បាប់ បានចំនួន ០១លើក ដែលមានអ្នកចូលរួមសរុប **៦០**នាក់ ស្រី **៣៤**នាក់។
- **ខេត្តព្រៃវែងៈ** បានផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងល្បិចបោកប្រាសរបស់ជនឆ្លៀតឱកាសមួយចំនួនតាមរយៈ៖
    - ពិធីសម្ពោធឆ្លងសាលាកត្ត និងសមិទ្ធផលនានានៅវត្តជ្រៃឧត្តម ក្រោមអធិបតីភាព ឯកឧត្តម **ជា សុមេធី** អភិបាលខេត្ត ប្រធានគណៈបញ្ជាការឯកភាពខេត្ត និងជាប្រធានគ.ខ.ប.ជ។
    - ការរៀបចំកម្មវិធីអបអរសាទរខួបលើកទី១១១ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២២ ដែលមានអ្នកចូលរួមសរុប **១.៤៤៦**នាក់ ស្រី **១.២៧៨**នាក់។
- **ខេត្តកំពង់ឆ្នាំងៈ** មន្ទីរអប់រំ យុវជន និងកីឡា បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនឹងការជួញដូរមនុស្ស តាមរយៈការចុះពិនិត្យថ្នាក់មត្តេយ្យសិក្សាសហគមន៍ ការចុះចងក្រងក្រុមសមាជិកមាតាបិតាថ្មី របស់គម្រោងហ្វ្រីន ការចុះទស្សនកិច្ចសិក្សា ការបើកវគ្គបំប៉នទឹកស្អាត និងអនាម័យ ការដាំបន្លែដល់សាលា

រៀន ការពិនិត្យតាមដានលើការងារគ្រប់គ្រងដឹកនាំ និងការរៀនបង្រៀនក្នុងឆ្នាំសិក្សា ២០២១-២០២២ និងការពិនិត្យតាមដាន រៀបចំរចនាសម្ព័ន្ធ និងពង្រឹងសមត្ថភាពមេដឹកនាំក្រុមប្រឹក្សាយុវជន កុមារ ចំនួន ០៦លើក។

**ខ.១.១.៣.ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ** បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមរយៈផេកហ្វេកប៊ុក មានអ្នកចូលមើលចំនួន **២៧.៩០៧**នាក់។
- **ខេត្តសៀមរាប៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM103MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីកិច្ចការពារជនរងគ្រោះ វិធានការទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអ៊ីនធឺណិត ការស្វែងរកការងារក្នុងស្រុកជាជាងការចំណាកដោយប្រថុយប្រថាន ការស្វែងរកជំនួយពីអាជ្ញាធរ និងអង្គការសង្គមស៊ីវិល ចំនួន **២០០**លើក (ផ្សាយផ្ទាល់ **៧៩**លើក និងចាក់ផ្សាយឡើងវិញ **១១៣**លើក)។
- **ខេត្តតាកែវ៖** មន្ទីរព័ត៌មានខេត្ត បានផ្សព្វផ្សាយ៖
    - ច្បាប់ និងសកម្មភាពនានាពាក់ព័ន្ធនឹងការបង្ក្រាបអំពើជួញដូរមនុស្ស កិច្ចការពារជនរងគ្រោះដោយអំពើរជួញដូរ និងការធ្វើអាជីវកម្ម ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការចូលរួមទប់ស្កាត់ជំងឺកូវីដ-១៩ តាមវិទ្យុ និងទូរទស្សន៍គោកធ្លក បាន **១៧៦**ដង សរុបចំនួន **៥.៤៥២**អត្ថបទ/លើក។
    - ព័ត៌មានតាមស្ថានីយ៍វិទ្យុFM92.5MHz អំពីសកម្មភាពនានាពាក់ព័ន្ធ ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរ ការធ្វើជីវកម្មផ្លូវភេទ និងផ្សព្វផ្សាយច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការប្រើប្រាស់គ្រឿងញៀន និងឃ្លីបអប់រំផ្សេងៗសរុបចំនួន **២.០៩៧**លើក/អត្ថបទ។
- **ខេត្តកំពង់ឆ្នាំង៖ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត** បានបញ្ជ្រាបចំណេះដឹងពាក់ព័ន្ធនិងការជួញដូរមនុស្សតាមរយៈការប្រជុំតាមប្រព័ន្ធ Telegram ឬ Google Meet ទៅដល់លោកប្រធានការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង/ស្រុកទាំង៨ ដើម្បីឲ្យលោកប្រធានការិយាល័យ ធ្វើការផ្សព្វផ្សាយបន្តទៅដល់ នាយក នាយិកា សិស្សានុសិស្ស នៅពេលគោរពទង់ជាតិមុនចូលរៀន និងក្នុងម៉ោងសិក្សាចំពោះមេរៀនដែលពាក់ព័ន្ធ។
- **ខេត្តព្រៃវែង៖** មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយសារអប់រំតាមវិទ្យុបាពយណ៍អណ្តែត FM-30 MHz ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១៥៥**លើក ក្នុងមួយថ្ងៃ ០៥លើក។
- **ខេត្តត្បូងឃ្មុំ៖** បានផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ស្តីពីភូមិឃុំមានសុវត្ថិភាព គ្រឿងញៀន អំពើហិង្សាក្នុងគ្រួសារ និងការអប់រំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ចំនួន ០១លើក។

**ខ.១.១.៤.ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិន៖**
    - ក្នុងកិច្ចពិភាក្សាលើប្រធានបទ "ការផ្សព្វផ្សាយនៃការសិក្សា ស្តីពីផលប៉ះពាល់សេដ្ឋកិច្ចសង្គមនៃបរិបទកូវីដ-១៩ លើបញ្ហាពលករទេសន្តរប្រវេសន៍នៅកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងប្រទេសថៃ" ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ
    - ក្នុងវេទិកា ស្តីពី "មោទនភាពស្ត្រីពលករចំណាកស្រុក" ដែលរៀបចំដោយស្ថានីយវិទ្យុស្ត្រី ១០៣.៥ និងបានប្រព្រឹត្តទៅនាថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២។

- **ខេត្តកំពង់ចាម៖**
  - ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម បានចូលរួមជាវាគ្មិន ក្រោមប្រធានបទ ស្តីពី៖ ១-«ការផ្សព្វផ្សាយពីនិតិវិធីដល់ប្រជាពលរដ្ឋ ដែលបានរៀបអាពាហ៍ ពិពាហ៍ជាមួយជនបរទេស» ០១លើក។ ២-ការពង្រឹងប្រសិទ្ធភាពផ្សព្វផ្សាយនីតិវិធីដល់ប្រជាពលរដ្ឋដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ចំនួន ០១លើក។
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិន៖ ១-ក្រោមប្រធានបទ បានចូលរួមជាវាគ្មិន ក្នុងសិក្ខាសាលា បិទបញ្ចប់គម្រោង ស្តីពីការលើកកម្ពស់ និងការការពារសិទ្ធិរបស់ពលករកម្ពុជាដែលមានជំនាញទាបនៅប្រទេសថៃ" ដែលអនុវត្តដោយ អង្គការ LSCW និង We World ០១លើក។ ២-ស្តីពីការអប់រំផ្សព្វផ្សាយចំណេះដឹងដល់ប្រជាពលរដ្ឋ ពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ពង្រឹងប្រសិទ្ធភាពផ្សព្វផ្សាយ និងទប់ស្កាត់ការធ្វើចំណាកស្រុកដោយខុសច្បាប់ ការទប់ស្កាត់ភាពមិនប្រក្រតីក្នុងថ្ងៃទិវាបុណ្យនៃក្តីស្រលាញ់ និងការបណ្តុះបណ្តាលជំនាញជាំផុះដល់ស្ត្រី ដើម្បីលើកស្ទួយជីវភាពគ្រួសារ បានចំនួន ០៤លើក។ ៣-ស្តីពីការការពារសិទ្ធិរបស់ពលករដែលមានជំនាញទាបនៅប្រទេសថៃ។
- **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានរួមចូលជាវាគ្មិននៅក្នុងវេទិកាផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ឱកាសស្វែងរកការងាររបស់ប្រជាពលរដ្ឋ និងវិធានការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ នៅស្រុកកំរៀង និងស្រុកសំពៅលូន ០១លើក។

**ខ.១.១.៥ ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** បានផ្សព្វផ្សាយ និងចែកខិត្តបណ្ណព័ត៌មានអំពីការធ្វើទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាពដល់ពលករទេសន្តរប្រវេសន៍ និងប្រជាពលរដ្ឋដែលមានបំណងធ្វើទេសន្តរប្រវេសន៍ការងារ ដោយសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច តាមរយៈមណ្ឌលធនធានពលករ (MRC) ខេត្តសៀមរាប ខេត្តកំពង់ធំ ខេត្តបាត់ដំបង និងខេត្តកំពត
- **ខេត្តបន្ទាយមានជ័យ៖**
  - អង្គការសាម៉ារីតាន់ភឺស ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន **៧.៩៨៧**នាក់ (ស្ត្រី **៣.២៧៥**នាក់) អនីតិជន **៣៥៥**នាក់។
  - អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន **៧.០៥៤**នាក់។
  - អង្គការដំណក់ទឹកផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន **៧.០៥៤**នាក់។
- **ខេត្តបាត់ដំបង៖** អង្គការសាម៉ារីតាន់ភឺស បានផ្តល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំនួន **៥៥០**នាក់ (ស្ត្រី **២៧៨**នាក់) កុមារ **៥០**នាក់។

**ខ.២. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ**

***ខ.២.១. ការបង្កើតកម្មវិធីសិក្សា ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស***

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ:**
  - បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការត្រៀមលក្ខណៈសម្បត្តិក្នុងការស្វែងរកការងារធ្វើចំនួន **៥**វគ្គ ដែលមានអ្នកចូលរួមសរុប **១៥០**នាក់។
  - បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីជំនាញទន់ចំនួន **៣**វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន **៧៥**នាក់។
  - បានផ្តល់សេវាប្រឹក្សាយោបល់ អំពីអាជីពការងារ និងវិជ្ជាជីវៈដល់អ្នកមកទទួលសេវា ចំនួន **១ ៩០៦**នាក់។

- ○ បានចាប់ផ្ដើមដាក់ឱ្យដំណើរការជាផ្លូវការប្រព័ន្ធជាតិអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈការងារពីចម្ងាយ ឬតាមអនឡាញ (National TVET E-learning Platform)។
- ○ បានពង្រឹង និងបង្កើនការផ្សព្វផ្សាយអំពីវិស័យអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈការងារ ដោយបាន៖ ១-ផ្សព្វផ្សាយតាមប្រព័ន្ធ Online ចំនួន ២ ៥៨៥ដង។ ២-ចងក្រង និងផលិតស្ពតផ្សព្វផ្សាយចំនួន ៣៦ដង។ ៣- ចុះផ្សព្វផ្សាយតាមភូមិភាគចំនួន ៥ដង។ ៤-ធ្វើកម្មវិធី Roadshow និងផ្សព្វផ្សាយនៅតាមសហគមន៍បានចំនួន ៤៣ដង ដែលមានសិស្សចំនួន ៣.៥៤៣នាក់ (ស្រី ១.៨៤៤នាក់)។

**ខ.២.២. វិធានការបង្ការ ទប់ស្កាត់ ដោយការគ្រប់គ្រងចំណាកស្រុកខុសច្បាប់**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ៖** កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្ត ចំនួន ០៣(នគរបាល និងយោធា) បានធ្វើការទប់ស្កាត់ ពលករចំណាកស្រុកខុសច្បាប់នៅតាមបន្ទាត់ព្រំដែនកម្ពុជា-ថៃ ចំនួន ១៨លើក មនុស្ស ៣១៥នាក់ (ស្រី ១២៧នាក់) អនីតិជន ៦២នាក់ បានធ្វើកិច្ចសន្យាការអប់រំណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ ទៅក្រៅប្រទេសទៀត និងបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ក្នុងនោះមាន៖
  - ○ ខេត្តបាត់ដំបង ចំនួន ០៥លើក មនុស្សចំនួន ១០០នាក់(ស្រី៤៦នាក់) អនីតិជន ២៥នាក់ ។
  - ○ ខេត្តបន្ទាយមានជ័យ ចំនួន ១២លើក មនុស្សចំនួន ២០៦នាក់(ស្រី៧៧នាក់) អនីតិជន ៣៧នាក់
  - ○ ខេត្តឧត្តរមានជ័យ ចំនួន ០១លើក មនុស្សចំនួន ០៩នាក់ (ស្រី ០៤នាក់)។

✓ **ក្រោយពីបានទទួល និងឃាត់ខ្លួនពលរដ្ឋទាំងនោះ ក៏បានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឲ្យចំណាកស្រុកខុសច្បាប់ទៅក្រៅប្រទេសទៀត ហើយឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ និងបញ្ជូនមេខ្យល់ ០១នាក់ទៅតុលាការដើម្បីចាត់ការតាមនីតិវិធី។**

**ខ.២.៣. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ**

▪ **ថ្នាក់ជាតិ៖**

- **ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បាន៖**
  - បានចុះអធិការកិច្ចការងារលើលក្ខខណ្ឌនៃការងារទូទៅចំនួន ៤៤លើក ក្នុងនោះការចុះធ្វើអធិការកិច្ចការងារសាមញ្ញចំនួន ២៤លើក និងអធិការកិច្ចការងារពិសេសចំនួន ២០លើក និងបានដាក់កំហិតរោងចក្រ សហគ្រាសចំនួន ៣២ និងផាកពិន័យរោងចក្រ សហគ្រាសចំនួន ៦។
  - បានរៀបចំវគ្គណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរទៅបរទេសចំនួន ២៥លើក ដែលមានពលករចំនួន ១.៦៥៧នាក់ (ស្រី ៦៨២នាក់)។
  - បានប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន ២៤.៥២២កន្លែង និងវគ្គអប់រំបណ្ដុះបណ្ដាល និងអាហារូបករណ៍ចំនួន ២៤៦វគ្គ ពីគ្រប់ប្រភព។
  - បានរៀបចំសិក្ខាសាលា ស្ដីពីផែនការអាជីព និងជ្រើសរើសការងារជំនាញសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិចំនួន ១៨១វគ្គ ដែលមានអ្នកចូលរួមសរុបចំនួន ៩.១០៩នាក់។
  - បានរៀបចំសិក្ខាសាលា ស្ដីពីការណែនាំអាជីពការងារ និងវិជ្ជាជីវៈ សម្រាប់សិស្ស និស្សិតនៅគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ និងសាកលវិទ្យាល័យចំនួន ៤វគ្គ ដែលមានអ្នកចូលរួមសរុប ២០៩នាក់។
  - បានរៀបចំពិព័រណ៍ចល័តចំនួន ១៨ដង ដែលមានអ្នកចូលរួមសរុបចំនួន ១.៦៥៦នាក់
  - បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រមូលអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋានចំនួន ៤ដង ដែលមានអ្នកចូលរួមសរុបចំនួន ២០០នាក់។
  - បានរៀបចំកម្មវិធីវេទិកាការងារចំនួន ១១ដង ដែលមានអ្នកចូលរួមសរុបចំនួន ៩១៦នាក់។
  - ប្រជាពលរដ្ឋ សិស្ស និស្សិតចូលប្រើប្រាស់គេហទំព័រការងារទីភ្នាក់ងារជាតិមុខរបរ និងការងារ មានចំនួន ៤៩.១២៦លើក

- ចំនួនអ្នកទទួលបានព័ត៌មានអំពីទីផ្សារការងារ តាមរយៈទំព័រ Facebook មានសរុបចំនួន ៣០.៥៤៧នាក់
- ចំនួនអ្នកប្រើប្រាស់សេវាតាមរយៈកម្មវិធីស្វែងរកការងារលើទូរស័ព្ទវៃឆ្លាតមានសរុប **៧៥**នាក់។

▪ **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(ស.អ.យ)៖**

- ក្រុមការងារការិយាល័យនីតិកម្ម និងអធិការកិច្ច បានចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលមានកិច្ចព្រមព្រៀង ជាមួយក្រសួង ស.អ.យ និងមណ្ឌលសំចត សរុបចំនួន ១៩មណ្ឌល (មជ្ឈមណ្ឌលរបស់អង្គការមាន ១៧មណ្ឌល និងមណ្ឌលសំចតប៉ោយប៉ែតរបស់នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះចំនួន០១កន្លែង) ដែលមានទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង និងខេត្តបន្ទាយមានជ័យ ដើម្បីត្រួតពិនិត្យដល់មជ្ឈមណ្ឌលទាំងអស់នោះត្រូវតែអនុវត្តទៅតាមគោលការណ៍ណែនាំរបស់ក្រសួង។
- ក្រុមការងារការិយាល័យគ្រប់គ្រងករណី និងការិយាល័យសង្គ្រោះ បានសហការជាមួយបណ្តាញ(3PC) ធ្វើការចុះស្វែងរក និងប៉ាន់ប្រមាណគ្រួសាររងគ្រោះដោយអំពើជួញដូរមនុស្ស មុនមាតុភូមិនិវត្តន៍ ដើម្បីបញ្ជូនជនរងគ្រោះទៅទទួលសេវាបន្តនៅអង្គការដៃគូ និងទៅសហគមន៍វិញ បន្ទាប់ធ្វើចត្តាឡីស័ក្តរួចដោយមានការគាំទ្រពីអង្គការយូនីសេហ្វ។

▪ **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- បានដាក់ចេញនូវវិធានការគ្រប់គ្រងស្ថានភាព ការទទួល ការបញ្ជូនពលករតាមបណ្តាច្រកព្រំដែន និងការធ្វើសមាហរណកម្មតាមបណ្តាមូលដ្ឋានថ្នាក់ក្រោមជាតិ ដោយរក្សាសុវត្ថិភាពសុខភាព តាំងពីដំណាក់កាលដំបូង នៃការប្រកាសបិទព្រំដែនរបស់ថៃ។
- បានសហការជាមួយអង្គការការីតាស់ស្វីស បង្កើតមណ្ឌលទទួលពលករកំរៀង ក្នុងខេត្តបាត់ដំបង ដើម្បីដោះស្រាយបញ្ហាពលករដែលឆ្លងកាត់ព្រំដែន។

▪ **អង្គការដៃគូ៖**

- **អង្គការអេ២១ អង្គការក្តីស្រឡាញ់គ្មានព្រំដែន អង្គការគ្រួសារថ្មី និងអង្គការយូនីសេហ្វ** បានសហការជាមួយប្រធានក្រុមការងារ និងមន្ត្រីមជ្ឈមណ្ឌលសំចតបោយប៉ែត បានសួរសុខទុក្ខករណីកុមាររងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន ០៣នាក់ និងគ្រួសាររបស់កុមាររងគ្រោះចំនួន ០២គ្រួសានៅក្នុងសហគមន៍ ដែលមានទីតាំងនៅក្នុងសៀមរាប ខេត្តសៀមរាប និង(ស្រុកមង្គលបុរី/ក្រុងប៉ោយប៉ែត) ខេត្តបន្ទាយមានជ័យ។

▪ **ថ្នាក់ក្រោមជាតិ៖**

• **លេខាធិការដ្ឋានរាជធានី ខេត្ត** បានធ្វើសេចក្តីរាយការណ៍ជាប្រចាំអំពីពលករ និងពលរដ្ឋ ដែលវិលត្រឡប់ពីបរទេស ដើម្បីតាមដានស្ថានភាពសុខភាព ជីវភាព និងធ្វើការអប់រំបង្ការទប់ស្កាត់ ការវិលត្រឡប់ទៅប្រទេសគោលដៅដោយប្រថុយប្រថាន តាមការញុះញង់ពីមេខ្យល់ និងសហការជាមួយអង្គការដៃគូ ដើម្បីធ្វើការប៉ាន់ប្រមាណអំពីភាពប្រឈម និងសេចក្តីត្រូវការ ក្នុងពេលធ្វើសមាហរណកម្ម និងបានសហការជាមួយអង្គការដៃគូ សប្បុរសជន ផ្តល់ការឧបត្ថម្ភគាំទ្រផ្នែកសុខភាព និងជីវភាព។

### ខ.២.៤. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក និងចំណូលស្រុក

នៅក្នុងត្រីមាសទី១ ឆ្នាំ២០២២នេះ តាមរបាយការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពលករខ្មែរដែលបានបញ្ជូនទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងតាមរយៈប្រព័ន្ធអនុគ្រោះមុខរបរ Employment Permit System(EPS) របស់រាជរដ្ឋាភិបាល មានចំនួនសរុប ១.៨៣០នាក់(ស្រី **៧៨៩**នាក់) ក្នុងនោះមាន៖

- សាធារណរដ្ឋកូរ៉េ ចំនួន ៦៨០នាក់ ស្រី ២៤៤នាក់

- ប្រទេសជប៉ុន ចំនួន ២៣៥នាក់ ស្រី ១១៦នាក់
- ប្រទេសថៃ ចំនួន ៩០៤នាក់ (ស្រី ៤១៨នាក់)
- ប្រទេសសិង្ហបុរី ចំនួន ០៨នាក់ ស្រី ០៨នាក់
- តំបន់រដ្ឋបាលពិសេសហុងកុង ចំនួន ០៣នាក់ ស្រី ០៣នាក់។

• **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានៈ

១-ដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងពលករទៅធ្វើការនៅក្រៅប្រទេស សម្រាប់ទីភ្នាក់ងារជ្រើសរើសឯកជន និងប្រព័ន្ធតាមដាន ជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករ រហូតដល់ពលករវិលត្រឡប់មកមាតុប្រទេសវិញ។

២-បានរៀបចំ និងពង្រឹងប្រព័ន្ធ OCWC (Oversea Cambodian Working Card) ពាក់ព័ន្ធនឹងពលករទេសន្តរប្រវេសន៍ ដូចជាការបែងចែកទៅតាមភេទ អាយុ កម្រិតអប់រំ និងប្រភេទការងាររបស់ពលករជាដើម សម្រាប់ធ្វើជាធាតុចូល ក្នុងការរៀបចំគោលនយោបាយ ឬបទដ្ឋានគតិយុត្ត។

៣-បានពង្រឹងប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីតាមដានលំហូរនីតិវិធីនៃការធ្វើទេសន្តរប្រវេសន៍ការងារនៅគ្រប់ប្រទេសទទួល។

• **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ទាំង២៥ បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរធ្វើចំណាកស្រុកទៅក្រៅប្រទេស ទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ១៤៣.៨៤០នាក់(ស្រី ៦៥.៥៨៨នាក់) អនីតិជន ១.៥០៣នាក់(ស្រី ៦១០នាក់)។ រួមមានៈ
  - ចេញដោយស្របចំនួន ៩១.៧៧១នាក់(ស្រី៤៣.៥៩១នាក់) អនីតិជន ២៩៣នាក់(ស្រី ១២៩នាក់។
  - ចេញដោយមិនស្របច្បាប់ចំនួន ៥១.៦៧០នាក់(ស្រី ២១.៨៥៦នាក់) អនីតិជន ១.២០៣នាក់(ស្រី ៤៧៦នាក់)។
  - ដាច់ការទាក់ទងចំនួន ៣៩៩នាក់(ស្រី ១៤១នាក់) អនីតិជន ០៧នាក់(ស្រី ០៥នាក់)។
- ទិន្នន័យពលរដ្ឋខ្មែរធ្វើចំណាកស្រុក ត្រឡប់ពីក្រៅប្រទេសដោយខ្លួនឯង ទាំងស្របច្បាប់ និងមិនស្របច្បាប់ពីស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត សរុបចំនួន ១២៤.១៣៦នាក់(ស្រី ៥៦.៥៧០នាក់) អនីតិជន ២.០៥៤នាក់(ស្រី ៩៥៦នាក់)។
- **រដ្ឋបាលរាជធានី ខេត្ត ចំនួន ១៦** ចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ២០២២ បានប្រមូលទិន្នន័យជាប្រចាំនូវចំនួនពលករវិលត្រឡប់ជារៀងរាល់ថ្ងៃ សរុបប្រមាណ ៩៤,៣៣៩នាក់ មានស្ត្រីប្រមាណ ៣៩,០៤៩នាក់ (៤១.៣៩%) ដែលភាគច្រើន មិនមានសេសសល់ប្រាក់ចំណូលសម្រាប់ការផ្គត់ផ្គង់ខ្លួន ឬគ្រួសារនៅឯស្រុកទេ។

*តារាងពលករវិលត្រឡប់គិតពីខែមករា ដល់ខែមីនា ឆ្នាំ២០២២*

| ល.រ | ខេត្ត | ចំនួនអ្នកវិលត្រឡប់សរុប | ស្ត្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | ព្រៃវែង | ២១៣ | ៨៦ | |
| ២ | ស្វាយរៀង | ១០ | ០១ | |
| ៣ | កំពត | ១៣៤ | ១៣៦ | |
| ៤ | តាកែវ | ៤១៦ | ១០៧ | |
| ៥ | កែប | ០៣ | ០២ | |
| ៦ | កោះកុង | ១.៣៩៤ | ៤៨២ | |
| ៧ | ក្រចេះ | ១.២១៤ | ៤៩៨ | |

| | | | | |
|---|---|---|---|---|
| ៨ | ត្បូងឃ្មុំ | ៨.៤៤៩ | ៣.៤០៦ | |
| ៩ | ឧត្តរមានជ័យ | ១.០៧៨ | ៥៣៦ | |
| ១០ | បន្ទាយមានជ័យ | ៣៨.០៣៤ | ១៥.៤៩៦ | |
| ១១ | ប៉ៃលិន | ៩.៤២៣ | ៣.៥៨២ | |
| ១២ | បាត់ដំបង | ៦៥៥ | ៣១២ | |
| ១៣ | ពោធិសាត់ | ២៣ | ១៣ | |
| ១៤ | កំពង់ឆ្នាំង | ២១ | ០៧ | |
| ១៥ | ព្រះវិហារ | ០៨ | ០៦ | |
| ១៦ | សៀមរាប | ៣៣.២៦៥ | ១៤.៣៧៩ | |
| សរុប | | ៩៤.៣៣៩ នាក់ | ៣៩.០៤៩ នាក់ | |

**ខ.២.៥. វិធានការគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
  - ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ កំពត ព្រៃវែង ក្រចេះ និងខេត្តរតនគិរី ល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ បានចំនួន ២០លើក។
  - ស្នងការដ្ឋាននគរបាលខេត្តតាកែវ កែប ក្រចេះ ព្រៃវែង កោះកុង និងខេត្តព្រះសីហនុ បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ជារកម្ម ដល់ម្ចាស់ជាជីវកម្មផ្ទះសំណាក់ ហាងម៉ាស្សា ជាប្រចាំក្នុងនោះ៖
    - ✓ ខែមករា ចំនួន **១៥១**គោលដៅ មនុស្សចំនួន **២០៤**នាក់ (ស្រី **១៤៨១**នាក់)
    - ✓ ខែកុម្ភៈ ចំនួន **១៥៩**គោលដៅ មនុស្សចំនួន **២៨៥**នាក់ (ស្រី**២០៩**នាក់)
    - ✓ ខែមិនា ចំនួន **១៧៧**គោលដៅ មនុស្សចំនួន **៣០១**នាក់ (ស្រី **២២៥**នាក់)។

**ខ.២.៦. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន **៣៧២**នាក់(ស្រី **៥៨**នាក់) ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ និងបានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងចំនួន **៣៦**នាក់(ស្រី **១៦**នាក់)។

**ខ.៣. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖
  - ចូលរួមជាគណៈអធិបតីក្នុងកម្មវិធីចែកសម្ភារសិក្សា និងកង់ដល់កុមារ ក្នុងគម្រោងកិច្ចអន្តរាគមន៍ស្នូលក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងសិប្បកម្មដំឡូងមី ដើម្បីឱ្យកុមារបានចូលសិក្សា ក្នុងខេត្តគោលដៅចំនួន៥ រួមមានខេត្តសៀមរាប ត្បូងឃ្មុំ ពោធិ៍សាត់ បាត់ដំបង និងខេត្តកំពង់ចាម ដែលមានអ្នកចូលរួមសរុបចំនួន ១.១០២នាក់ (ស្រី **៤៥៣**នាក់)។
  - បានផ្តល់ទិដ្ឋាការប្រើប្រាស់កម្មករនិយោជិតវ័យក្មេងចំនួន ៤សហគ្រាស។
  - បានផលិតវីឌីអូស្ពត ស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។

- បានចូលរួមសិក្ខាសាលា ស្តីពីការអនុវត្តសាកល្បងនៃការចុះធ្វើអធិការកិច្ចការងារ តាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២២។
- បានរៀបចំកិច្ចប្រជុំបន្ត ដើម្បីពិនិត្យ និងកែសម្រួលកម្រងសំណួរក្នុងការចុះអធិការកិច្ចលើសិប្បកម្មផលិតឥដ្ឋ និងចម្ការដំឡូងមី ដើម្បីជៀសវាងការងារដោយបង្ខំ និងពលកម្មកុមារ។

- **ខេត្តក្រចេះ៖**
  - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះកុមារ នៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ខេត្តក្រចេះ ០២លើក ជាលទ្ធផលឃើញថា ការថែទាំ និងការឧបត្ថម្ភដល់កុមារ បានដំណើរការល្អប្រសើរ។
  - មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានចុះទៅណែនាំផ្សព្វផ្សាយករណីពលកម្មកុមារ នៅតាមបណ្តារោងចក្រសិប្បកម្ម ទឹកពិសារដប ជញ្ជីងថ្លឹងទំងន់(ជញ្ជីងតោន)ស្ថានីយ៍ប្រេងឥន្ធនៈបានចំនួន ២១មូលដ្ឋាន មានបុគ្គលិកចំនួន ៦២នាក់ ស្រី ២៣នាក់ មានខ្លឹមសារដូចជា ដើម្បីទប់ស្កាត់ជួញដូរកម្លាំងពលកម្មកុមារ និងទប់ស្កាត់រាល់សកម្មភាពជួញដូរ និងប្រើអំពើហិង្សាលើបុគ្គលិកកម្មករ (ពិសេសកុមារ)។
- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះទៅណែនាំផ្សព្វផ្សាយករណីពលកម្មកុមារនៅតាមឡឥដ្ឋ រោងចក្រសហគ្រាស កន្លែងលាងឡាន និងកន្លែងកំសាន្ត និងបានផ្សព្វផ្សាយដល់សហគមន៍ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស តាមរយៈការចុះពិនិត្យតាមដាន ការប្រជុំក្រុមឪពុកម្តាយកុមារតូចអាយុ ០ឆ្នាំ ដល់៣ឆ្នាំ តាមស្រុក ឃុំ ភូមិគោលដៅមួយចំនួន។
- **ខេត្តប៉ៃលិន៖** បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សែឡ កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៨០កន្លែង ជាលទ្ធផលរកពុំឃើញមានជួញដូរកម្លាំងពលកម្មកុមារទេ។
- **ខេត្តសៀមរាប៖**
  - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បាន៖ ១-ចុះតាមដានការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យកសិកម្ម (ដំឡូងមី) ព្រមទាំងបានធ្វើការផ្សព្វផ្សាយអំពីប្រកាសពាក់ព័ន្ធនឹងពលកម្មកុមារក្នុងវិស័យកសិកម្ម ដល់អាណាព្យាបាល និងកុមារ នៅស្រុកអង្គរជុំ បានចំនួន ០១លើក ដែលមានអ្នកចូលរួមសរុប ៥០នាក់ ស្រី ២២នាក់។ ២-សហការជាមួយស្នងការដ្ឋាននគរបាលខេត្ត និងកងរាជអាវុធហត្ថខេត្ត បានធ្វើការប្រជុំពិភាក្សាលើការកំណត់នីតិវិធីក្នុងការទប់ស្កាត់ និងដកហូតកុមារក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ នៅតាមសហគ្រាសអាជីវកម្មផលិតឥដ្ឋ បានចំនួន ០១លើក ដែលមានអ្នកចូលរួមសរុប ០៨នាក់ ស្រី ០៤នាក់។ ៣-ចុះតាមដានការប្រើប្រាស់ពលកម្មកុមារក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ ព្រមទាំងបានធ្វើការផ្សព្វផ្សាយបន្ថែមអំពីកម្រងប្រកាសទាំង១៣ ពាក់ព័ន្ធនឹងទម្រង់ពលកម្ម និងសេចក្តីណែនាំលេខ០៥៦/១៩ ក.ប/ស.ណ.ន.ខ.ល ស្តីពី ការហាមក្មេងចូលទៅក្នុងបរិវេណខ្សែចង្វាក់ផលិតកម្មផលិតឥដ្ឋ ដល់ម្ចាស់អាជីវកម្ម អាណាព្យាបាល និងកុមារនៅឃុំដានរុន ស្រុកសូទ្រនិគម បានចំនួន ០១លើក ដែលមានអ្នកចូលរួមសរុប ៥០នាក់ ស្រី ២៦នាក់។ ៤-ចុះស្រង់ស្ថិតិកម្មករ និងកុមារ ដែលស្នាក់ជាមួយឪពុកម្តាយនៅក្នុងសិប្បកម្មផលិតឥដ្ឋ ព្រមទាំងបានធ្វើការផ្សព្វផ្សាយបន្ថែម អំពីកម្រងប្រកាសទាំង១៣ ពាក់ព័ន្ធនឹងទម្រង់ពលកម្ម និងសេចក្តីណែនាំលេខ០៥៦/១៩ ក.ប/ស.ណ.ន.ខ.ល ស្តីពី ការហាមក្មេងចូលទៅក្នុងបរិវេណខ្សែចង្វាក់ផលិតកម្មផលិតឥដ្ឋ ដល់ម្ចាស់អាជីវកម្ម អាណាព្យាបាល និងកុមារ នៅស្រុកជីក្រែង បានចំនួន ០១លើក។

• **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានដាក់បណ្តាញម៉ូតូឌុប និងក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ បណ្តាញតាមសហគមន៍ ផ្នែកភ្នាក់ងារទេសចរណ៍សរុបចំនួន ១.១៣៣នាក់។

• **ខេត្តរតនគិរី៖** មន្ទីរអប់រំ យុវជន និងកីឡា បានចុះពង្រឹងការងារក្រុមប្រឹក្សាកុមារកម្ពុជា និងបានធ្វើការផ្សព្វផ្សាយអំពីច្បាប់ពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញមនុស្ស ការរំលោភបំពាននានាលើកុមារ ការប្រើប្រាស់គ្រឿងញៀន ជូនដល់លោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស ប្រធានប្រតិបត្តិ ប្រធានសាខា ក្នុងបរិបទកូវីដ-១៩ នៅសាលាបឋមសិក្សាកាឡែង ស្រុកលំផាត់ និងក្រុងបានលុង មានអ្នកចូលរួមសរុប ៥៥នាក់។

• **ខេត្តមណ្ឌលគិរី៖** បានចុះអធិការកិច្ច ត្រួតពិនិត្យ និងស្រង់ស្ថិតិនៅតាមរីសិតនានាចំនួន ១៩រីសិត នៅជុំវិញខេត្ត ដើម្បីផ្សព្វផ្សាយច្បាប់ការងារ ស្តីពីការទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ ដែលមានកម្មករ និយោជកចូលរួមចំនួន ១១០នាក់(ស្រី ៣០នាក់)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន **៣៧**ករណី(ធៀបនឹងត្រីមាសទី១ ឆ្នាំ២០២១ មានចំនួន ៨៥ករណី ថយចុះចំនួន ៤៨ករណី) ស្មើនឹង **៥៦,៤៧%** ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៤៣នាក់ (ស្រី ០៦នាក) អនីតិជន ០២នាក់។ ក្នុងនោះជនសង្ស័យជាជនបរទេសចំនួន ០៧នាក់ មាន ០៣សញ្ជាតិ គឺជនជាតិចិន ០៥នាក់ ជនជាតិថៃ ០១នាក់ និងជនជាតិបង់ក្លាដេស ០១នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ៨៦នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ៣១នាក់ អាយុ១៥-១៧ឆ្នាំ ០៩នាក់ និងអាយុពី១៨ឆ្នាំឡើង ៤៦នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០៥នាក់ និងប្រគល់ឱ្យគ្រួសារ ៨១នាក់) ក្នុងនោះចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ១១ករណី/ ៥៧ករណី (ថយចុះ ៤៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៧នាក់ (ស្រី ០២នាក់) អនីតិជន ០១នាក់ និងជនបរទេស ០៦នាក់ មាន ០២សញ្ជាតិ មានជនជាតិចិន ០៥នាក់ និងជនជាតិថៃ ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៤៩នាក់ មាន៖ អាយុក្រោម១៥ឆ្នាំ ០៦នាក់ អាយុ១៥-១៧ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ៤២នាក់ (ប្រគល់ឱ្យគ្រួសារ ៤៩នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | មាត្រា | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១ | ០៦ | ២៩ | ០៨ | ថៃ០១ |
| - អំពើលក់ដូរមនុស្ស | ១៤ | ០១ | ០៤ | ០៥ | ចិន០៥ |
| -អំពើលក់ដូរមនុស្សសម្រាប់នាំឆ្លងដែន | ១៦ | ០១ | ០ | ០១ | |

| | | | | | |
|---|---|---|---|---|---|
| -ការដឹកជញ្ជូនដោយមានគោលដៅ<br>-ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស<br>-ការទិញពេស្យាចារកុមារ | ១៧<br>២០<br>៣៤ | ០១<br>០១<br>០១ | ១២<br>០៣<br>០១ | ០១<br>០១<br>០១<br>អនី.០១ | |
| *សរុប* | | *១១ករណី* | *៤៩ នាក់* | *១៧ នាក់* | *០៦នាក់<br>ចិន០៥ នាក់<br>ថៃ ០១នាក់* |

## ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន **២៦**ករណី/ **៣៣**ករណី (ថយចុះ **០៧**ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន **២៦**នាក់ (ស្រី ០៤នាក់) អនីតិជន **០១**នាក់ និងជនបរទេស **០១**នាក់ គឺជនជាតិបង់ក្លាដេស។ សង្គ្រោះជនរងគ្រោះចំនួន **៣៧**នាក់ មានៈ អាយុក្រោម១៥ឆ្នាំ **២៥**នាក់ អាយុ១៥-១៧ឆ្នាំ ០៨នាក់ និងអាយុ១៨ឆ្នាំឡើង ០៤នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច **០៥**នាក់ និងប្រគល់ឱ្យគ្រួសារ **៣២**នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | មាត្រា | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|---|
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ២៧ | ០១ | ០៥ | ០១ | |
| -សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមា | ២៨ | ០២ | ០៧ | ០២ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ៣៩ | ០១ | ០១ | ០១ | |
| -រូបភាព និងសម្ភារៈអាសអាភាស នៃកុមារ | ៤១ | ០១ | ០១ | ០១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៤២ | ១៦ | ១៨ | ១៦<br>(អនី.០១) | បង់ក្លាដេស<br>០១នាក់ |
| -អំពើអាសប្រឆាំងនឹងអនិតិជនអាយុក្រោម១៥ឆ្នាំ | ៤៣ | ០៥ | ០៥ | ០៥ | |
| *សរុប* | | *២៦ករណី* | *៣៧ នាក់* | *២៦នាក់*<br>(អនី.០១) | បង់ក្លាដេស<br>*០១ នាក់* |

### គ.២. កិច្ចការយុត្តិធម៌

#### គ.២.១. លទ្ធផលចំណាត់ការផ្តន្ទាទោស

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ ជាលទ្ធផលតាមដំណាក់កាលទាំង៣ នៃនីតិវិធីតុលាការ មានដូចខាងក្រោម៖

១. <u>ចំណាត់ការរបស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត</u> ៖

សរុបចំនួន **១០៥** សំណុំរឿង (រឿងសល់ពីមុន **២៣**សំណុំរឿង) ជនរងគ្រោះ **១៤៥**នាក់(ស្រី **២៧**នាក់) ក្នុងនោះអនីតិជន **៨២**នាក់(ស្រី **៧៤**នាក់) និងជនបរទេស ០៦នាក់ (ស្រី ០១នាក់)ជនល្មើសចំនួន **១៥៧**នាក់(ស្រី ០៩នាក់) ក្នុងនោះអនីតិជន ០១នាក់(ប្រុស) ជនបរទេស ៤១នាក់ (ស្រី ០២នាក់) និងអញ្ញាតជន ០២នាក់។

✓ **វត្ថុចាប់យកៈ** ទទួលបានពីនគរបាលយុត្តិធម៌មាន ថវិកាអាម៉េរិច **៧០១**ដុល្លារ រថយន្ត ០១គ្រឿង ម៉ូតូ ០៧គ្រឿង និងទូរស័ព្ទ ០១គ្រឿង។

✓ **សំណុំរឿងចាត់ការរួចៈ** បញ្ជូនទៅស៊ើបសួរ(RI)ចំនួន **៦៤**សំណុំរឿង បញ្ជូនរឿងទៅជម្រះ(CD) **០២** សំណុំរឿង តម្កល់រឿងទុកឥតចាត់ការ **០៥**សំណុំរឿង សរុប **៧១**សំណុំរឿង និងកំពុងចាត់ការចំនួន **៣៤**សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោមៈ

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនល្មើស | | | | | | សំណុំរឿងចាត់ការរួច | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | បញ្ជូនទៅស៊ើបសួរ | បញ្ជូនរឿងទៅជម្រះ | តម្កល់ទុកឥតចាត់ការ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | |
| ១០៥ | ៣០ | ២៧ | ០៨ | ៧៤ | ០៥ | ០១ | ១០៤ | ០៩ | ០១ | ០ | ៣៩ | ០២ | ៦៤ | ០២ | ០៥ | ៣៤ |
| សរុប | ៥៧នាក់ | | ៨២នាក់ | | ៦នាក់ | | ១១៣ | | ០១នាក់ | | ៤១ | | | | | |
| សរុបរួម | ១៤៥ នាក់ | | | | | | ១៥៧ នាក់(ក្នុងនោះអញ្ញាតជន០២នាក់) | | | | | | ៧១ សំណុំរឿង | | | ៣៤ សំណុំរឿង |

## ២. ចំណាត់ការរបស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានី-ខេត្ត ៖

សរុបចំនួន **១៩៥**សំណុំរឿង (រឿងសល់ពីមុន **១២៨**សំណុំរឿង) ជនរងគ្រោះ **២០៨**នាក់ (ស្រី **៣០**នាក់) ក្នុងនោះមានអនីតិជន **៥៨**នាក់(ស្រី **៥៣**នាក់) ជនបរទេស **៦៧**នាក់(ស្រី **១២**នាក់) ជនត្រូវចោទ **៥៨៧**នាក់ (ស្រី **១៨៩**នាក់) ក្នុងនោះមានអនីតិជន **៥៥**នាក់ (ស្រី **០៨**នាក់) ជនបរទេស **១១**នាក់(ស្រី **០០**នាក់) ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ **០០**សំណុំរឿង អញ្ញាតជន **០៣**នាក់ (**៣នាក់នេះពុំបានដាក់បញ្ចូលក្នុងតារាងខាងក្រោមទេ**)។

✓ **សំណុំរឿងចាត់ការរួចៈ** បញ្ជូនរឿងទៅជម្រះ **៦៦**សំណុំរឿង លើកលែងបទចោទ **០០**សំណុំរឿង ផ្ទេរសមត្ថកិច្ច **០៤**សំណុំរឿង សរុប **៧០**សំណុំរឿង និងកំពុងចាត់ការ **១២៥**សំណុំរឿង។ ដូចមានតារាងលម្អិតខាងក្រោមៈ

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនត្រូវចោទ | | | | | | សំណុំរឿងចាត់ការរួច | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | បញ្ជូនរឿងទៅជម្រះ | លើកលែងបទចោទ | ផ្ទេរសមត្ថកិច្ច | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | |
| ១៩៥ | ៥៣ | ៣០ | ០៥ | ៥៣ | ៥៥ | ១២ | ៣៣២ | ១៨៩ | ៤៧ | ០៨ | ១១ | ០០ | ៦៦ | ០០ | ០៤ | ១២៥ |
| សរុប | ៨៣ នាក់ | | ៥៨ នាក់ | | ៦៧ នាក់ | | ៥២១ នាក់ | | ៥៥ នាក់ | | ១១ នាក់ | | | | | |
| សរុបរួម | ២០៨ នាក់ | | | | | | ៥៨៧ នាក់ | | | | | | ៧០សំណុំរឿង | | | ១២៥សំណុំរឿង |

## ៣. ដំណាក់កាលចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានី-ខេត្ត៖

សរុបចំនួន **២៣៤**សំណុំរឿង (សល់ពីមុន **១១៧**សំណុំរឿង) ជនរងគ្រោះ **២៥៣**នាក់(ស្រី **៧២**នាក់) ក្នុងនោះអនីតិជន **១១០**នាក់ (ស្រី **៨៩**នាក់) ជនបរទេស **០៩**នាក់(ស្រី **០២**នាក់) ជនជាប់ចោទ **៤២០**នាក់(ស្រី **១០៩**នាក់)ក្នុងនោះអនីតិជន **១១**នាក់ (ស្រី **០៣**នាក់) ជនបរទេស **០០**នាក់ និងអញ្ញាតជន **០១**នាក់។ **សំណុំរឿងចាត់ការរួចៈ** បានជំនុំជម្រះ **៨៩**សំណុំរឿង ប្រកាសសាលក្រមឱ្យរួចផុតពីបទចោទ **០៩**សំណុំរឿង មនុស្សចំនួន**១៥** នាក់(ស្រី **០៩**នាក់) ពិន័យជាប្រាក់ **១០**សំណុំរឿង ដាក់ពន្ធនាគារ **៥៦**សំណុំរឿង មនុស្សសរុប **៧០**នាក់(ស្រី **៤០**នាក់) ទោសព្យួរសាកល្បង **០០**សំណុំរឿង ទោសព្យួរធម្មតា **០៦**សំណុំរឿង ចំនួនមនុស្ស **០១**នាក់ (ស្រី **០១**នាក់)។(**ចាប់ពីទោសព្យួរសាកល្បង ទោសព្យួរធម្មតា និងចំនួនមនុស្សមិនបានដាក់បញ្ចូលចំនួនទៅក្នុងតារាងខាងក្រោមទេ**)។

✓ បណ្ដឹងឧបាស្រ័យៈ បណ្ដឹងជំទាស់ ០០សំណុំរឿង បណ្ដឹងឧទ្ធរណ៍ ០១សំណុំរឿង។

✓ ប្រគល់វត្ថុចាប់យកឱ្យម្ចាស់ដើមៈ សម្ភារជារថយន្ត ០២គ្រឿង ទូរស័ព្ទ ០៤គ្រឿង និងរឿងកំពុងចាត់ការ ១៤៥សំណុំរឿង)។ ដូចមានតារាងលម្អិតខាងក្រោមៈ

| ចំនួនសំណុំរឿង | ចំនួនជនរងគ្រោះ | | | | | | ចំនួនជនត្រូវចោទ | | | | | | សំណុំរឿងចាត់ការរួច | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | នីតិជន | | អនីតិជន | | ជនបរទេស | | នីតិជន | | អនីតិជន | | ជនបរទេស | | បានជំនុំជម្រះ | លើកលែងបទចោទ | ពិន័យជាប្រាក់ | ដាក់ពន្ធនាគារ | កំពុងចាត់ការ |
| | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | | | | | |
| ២៣៤ | ៦២ | ៧២ | ២១ | ៨៩ | ០៧ | ០២ | ២៩៩ | ១០៩ | ០៨ | ០៣ | ០០ | ០០ | ៨៩ | ០៩ (មនុស្ស ១៥នាក់) | ១០ | ៥៦ (មនុស្ស ៧០នាក់ | ១៤៥ |
| សរុប | ១៣៤ នាក់ | | ១១០ នាក់ | | ០៩ នាក់ | | ៤១៨ នាក់ | | ១១ នាក់ | | ០០ នាក់ | | | | | | |
| សរុបរួម | ២៥៣ នាក់ | | | | | | ៤២០ នាក់(រួមទាំងអញ្ញាតជន០១នាក់) | | | | | | ៨៩សំណុំរឿង | | | | ១៤៥ សំណុំរឿង |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្ថានតំណាងនៅបរទេស បានសង្គ្រោះ ឧបត្ថម្ភ និងជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណបឋម រកភាពរងគ្រោះ និងបានធ្វើការសន្និដ្ឋានបឋមថា សង្ស័យជាករណីស្នាក់នៅ និងធ្វើការងារដោយខុសច្បាប់ សរុបចំនួន ៦.០២៩នាក់(ស្រី ៣.០០៨នាក់) ក្នុងនោះសង្ស័យថា រងគ្រោះដោយអំពើជួញដូរមនុស្ស ៣៤នាក់(ស្រី ៣៤នាក់) ដូចមានក្នុងតារាងខាងក្រោមៈ

| ល.រ. | ប្រទេសគោលដៅ | មូលហេតុនៃការវិលត្រឡប់ | សរុប | ស្រី |
|---|---|---|---|---|
| ១ | ម៉ាឡេស៊ី | ពលករខុសច្បាប់ | ១៨ | ០២ |
| ២ | ឥណ្ឌូនេស៊ី | ពលករខុសច្បាប់ | ០២ | ០២ |
| ៣ | ចិន | សង្ស័យជួញដូរ និងចាញ់បោកមេខ្យល់ | ៣៤ | ៣៤ |
| ៤ | សឹង្ហបុរី | ទ្រាំការងារមិនបាន | ០១ | ០១ |
| ៥ | វៀតណាម | ឆ្លងដែនខុសច្បាប់ | ១១ | ១១ |
| ៦ | ថៃ | ពលករខុសច្បាប់ | ៥.៩៥៩ | ២.៩៥៨ |
| ៧ | ឡាវ | ឆ្លងដែនខុសច្បាប់ | ០៤ | ០០ |
| សរុប | | | ៦.០២៩ នាក់ | ៣.០០៨ នាក់ |

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
    - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ នៃក្រសួង ស.អ.យ បានទទួល ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុប ៩៨នាក់(ស្ត្រី ៧៣នាក់ កុមារា ០២កុមារី ០៥នាក់) មកពីប្រទេសចិន ៦២នាក់ ម៉ាឡេស៊ី ២៤នាក់ វៀតណាម ០៧នាក់ ថៃ ០៤នាក់ និងនីហ្សេរីយ៉ា ០១នាក់ *(ករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ៦០នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ០៧នាក់ ជួញដូរកម្លាំងពលកម្ម ១៤នាក់ ជួញដូរផ្លូវភេទ ០២នាក់*

*ពពោះ ០២នាក់ ងាយរងគ្រោះ ១២នាក់ និងសង្ស័យថាជាមេខ្យល់ ០១នាក់)* បានសម្ភាសន៍កំណត់អត្តសញ្ញាណ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។

- **មណ្ឌលសំចតប៉ោយប៉ែត** បានទទួលពីប្រទេសថៃចំនួន ៤៥.៤០៣នាក់ (ស្ត្រី ១៨.៤៣៤នាក់) កុមារ ៣.០៣៨នាក់ (កុមារី ២.៧៥១នាក់) បានសម្ភាសន៍កំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ ដើម្បីផ្តល់សេវាជូនពលករមួយចំនួន ដែលមិនមានលទ្ធភាពត្រឡប់ទៅស្រុកកំណើតវិញ។

▪ **អគ្គស្នងការដ្ឋាននគរបាលជាតិ**

- **នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន** បានទទួល និងសម្ភាសន៍ជនរងគ្រោះ ដែលបាន វិលត្រឡប់មកពីក្រៅប្រទេស ចំនួន **៥៣**នាក់(ស្រី **៤៣**នាក់) មកពីប្រទេសចិន **៣៧**នាក់(ស្រី) អនីតិជន **០១**នាក់ និងម៉ាឡេស៊ី **១៦**នាក់ (ស្រី ០៦នាក់)។ ជាលទ្ធផលតាមរយៈអនឡាញ៖
  - ✓ រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈចំនួន **២៦**នាក់(ស្រី) នៅចិន
  - ✓ រងគ្រោះដោយការស្នាក់នៅដោយខុសច្បាប់ចំនួន **២៣**នាក់(ស្រី **១៤**នាក់) នៅចិន **១១**នាក់ (ស្រី) និងនៅម៉ាឡេស៊ី **១២**នាក់(ស្រី ០៣នាក់)។
  - ✓ រងគ្រោះដោយកេងប្រវ័ញ្ចប្រាក់ឈ្នួលនៅម៉ាឡេស៊ី ០៣នាក់(ស្រី) និងមិនរងគ្រោះ ០១នាក់។

  ជនរងគ្រោះខាងលើទៅតាមរយៈមេខ្យល់ផ្សេងៗគ្នាមិនស្គាល់អត្តសញ្ញាណ បច្ចុប្បន្នប្រគល់ឱ្យមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្តារនីតិសម្បទា។

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត** ស្នងការដ្ឋាននគរបាលខេត្ត ចំនួន ០២ បានទទួល និងសម្ភាសន៍ពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ និងច្រកទ្វារព្រំដែនអន្តរជាតិ កម្ពុជា-វៀតណាម សរុបមនុស្សចំនួន **១៥៣**នាក់(ស្រី **៦០**នាក់) អនីតិជន **១៣**នាក់ ក្នុងនោះមាន៖
  - ○ **ខេត្តបាត់ដំបង** ចំនួន ០១លើក មនុស្សចំនួន **១៥០**នាក់ (ស្រី **៥៧**នាក់) អនីតិជន **១៣**នាក់។
  - ○ **ខេត្តស្វាយរៀង** ចំនួន ០១លើក មនុស្សចំនួន ០៣នាក់ (ស្រី ០៣នាក់)។

**ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្សទៅស្តារនីតិសម្បទានៅមណ្ឌលរបស់អង្គការដៃគូ សរុប ៨៣៦នាក់(ស្ត្រី ៤១០នាក់ កុមារា ៧៤នាក់ កុមារី ៣៤៩នាក់) *ករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ៣៧នាក់ ករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ៤១នាក់ ជួញដូរកម្លាំងពលកម្ម០២នាក់ ជួញដូរផ្លូវភេទ ៣៧០នាក់ និងរំលោភបំពានផ្លូវភេទ ១២៨នាក់ សញ្ចារកម្ម ១៨នាក់ និងងាយរងគ្រោះ ២៤០នាក់*។

**ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ សមាហរណកម្ម ស្ត្រីរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទ ត្រឡប់ទៅសហគមន៍វិញសរុប ៣២នាក់(ស្រី ១៧នាក់) កុមារី ០១នាក់ ក្នុងនោះ *(ករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ១៨នាក់ ជួញដូរកម្លាំងពលកម្ម ១៤នាក់)*។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

**ក.១. ការងារបណ្តុះបណ្តាល**

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) បានសហការជាមួយក្រសួង ស្ថាប័ន អង្គការដៃគូពាក់ព័ន្ធ បើកវគ្គបណ្តុះបណ្តាលចំនួន ៦២វគ្គ មានសិក្ខាកាមចូលរួមចំនួន ២.១១១នាក់ ក្នុងនោះមានស្ត្រី ៨៦៧នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តច្បាប់ និងសមាជិក គ.រ.ប.ជ/គ.ខ.ប.ជ ដូចមានក្នុងតារាងខាងក្រោមៈ

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានសហការជាមួយអង្គការ ASEAN ACT **និងអង្គការមូលនិធិអេ២១** បើកវគ្គបណ្តុះបណ្តាលលើគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារជនរងគ្រោះ និងគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តសៀមរាប និងខេត្តបាត់ដំបង។ | ០៤ | ២១៨ | ៨៣ |
| **អគ្គស្នងការដ្ឋាននគរបាលជាតិ** នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានសហការជាមួយស្ថានទូតអាមេរិក(FBI) អង្គការសម្ព័ន្ធចាប់ដៃ(CHAB DAI) អង្គការសកម្មភាពដើម្បីកុមារ(APLE) អង្គការមេត្រីអន្តរជាតិ(AIM SWAT ) អង្គការជីវិតនៃកម្ពុជា អង្គការ Unicef និងអង្គការហាការ(HAGAR) បើកវគ្គបណ្តុះបណ្តាលជំនាញដល់នាយនគរបាល នៃស្នងការនគរបាលរាជធានី-ខេត្ត ស្តីពីៈ ១-ការកំណត់អត្តសញ្ញាណជនរងគ្រោះនិងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស។ ២-ការគាំទ្រដល់កុមាររងគ្រោះ និងបច្ចេកទេសក្នុងការធ្វើការជាមួយកុមារក្នុងនិតិវិធីព្រហ្មទណ្ឌនិងការឆ្លើយតបបទល្មើសផ្លូវភេទលើកុមារ។ ៣-សេចក្តីណែនាំអំពីការស៊ើបអង្កេតអំពើកេងប្រវ័ញ្ចកុមារ។ ៤-នីតិវិធី ស៊ើបអង្កេតការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើហឹង្សាទាក់ទងនឹងយេនឌ័រ។ | ០៩ | ៤៨៧ | ១០៥ |
| **អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានសហការជាមួយអង្គការវីនរ៉ក់ បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្របនៅខេត្តបាត់ដំបង។ | ០១ | ៣០ | ១២ |
| **អង្គការសាម៉ារីតាន់ភីស(ខេត្តបាត់ដំបង)ៈ** បានសហការជាមួយអាជ្ញាធរ ភូមិ/ឃុំ/ស្រុក បើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់មន្ត្រីស្ម័គ្រចិត្តភូមិ ដែលមកពីភូមិចំនួន ០៣របស់ស្រុកមោងឫស្សី និងភូមិចំនួន ០៤របស់ ស្រុកសង្កែ។ | ០៣ | ៩៥ | ០០ |
| **ខេត្តបន្ទាយមានជ័យៈ** បានរៀបចំបើកវគ្គបណ្តុះបណ្តាលឡើងវិញ ស្តីពីកិច្ចការពារកុមារ និងការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទលើកុមារ ដល់ក្រុមអ្នកស្ម័គ្រចិត្ត ដឹកនាំកុមារលេងកម្សាន្តនៅតាមសហគមន៍។ | ០១ | ១៤ | |

| | | | |
|---|---|---|---|
| **ខេត្តសៀមរាប៖**<br>-ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការជីវិតនៃកម្ពុជានិងអង្គការ Unicef បើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។<br>-ក្រុមការងារយុវជន នៅក្នុងឃុំកែវពណ៌ ស្រុកពួក បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។<br>-លេខាធិការដ្ឋាន បានសហការជាមួយ គ.ជ.ប.ជ និងអង្គការ IOM រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។<br>-មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បណ្តុះបណ្តាលស្តីពី បទប្បញ្ញត្តិពាក់ព័ន្ធនឹងទេសន្តរប្រវេសន៍ ដើម្បីស្វែងរកការងារប្រកបដោយសុវត្ថិភាព ការជ្រើសរើសប្រកបដោយក្រមសីលធម៌ និងសេវាកម្មដែលឆ្លើយតបនឹងយេនឌ័រ។ | ០២<br><br>០១<br><br>០១<br><br>០៤ | ១០៤<br><br>៣២<br><br>២០<br><br>១០៣ | ១៦<br><br>១៩<br><br>០៩<br><br>៤០ |
| **ខេត្តព្រះវិហារ៖** មន្ទីរកិច្ចការនារី សហការជាមួយអង្គការ UNFPA បើកវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសផ្លូវច្បាប់ពាក់ព័ន្ធជនរងគ្រោះដោយអំពើជួញដូរមនុស្ស យេនឌ័រ អំពើហិង្សា និងការរំលោភបំពានផ្លូវភេទលើកុមារ។ | ០១ | ៣៨ | ១៧ |
| **ខេត្តស្វាយរៀង**<br>-មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស នៃក្រសួងសង្គមកិច្ច និងអង្គការ IJM បើកវគ្គបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងករណីដល់មន្ត្រីសង្គមកិច្ចខេត្ត និងក្រុង ស្រុកទាំង៨។<br>-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន ១២ បើកវគ្គបណ្តុះបណ្តាល ដោយបានបញ្ជ្រាបការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទ ស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារ សុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម។ | ០១<br><br>១៦ | ១៩<br><br>៣០៩ | ០៦<br><br>១៤៨ |
| **ខេត្តតាកែវ** ប្រធានក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជខេត្តបាន៖<br>-សហការជាមួយអង្គការម្លប់ឫស្សី បើកវគ្គបណ្តុះបណ្តាល ស្តីពី បណ្តាញកិច្ចការពារកុមារដល់មន្ត្រីផ្តល់សេវាសង្គមកិច្ច និងអ្នកពាក់ព័ន្ធថ្នាក់ឃុំ សង្កាត់ ដល់សមាសភាព គ.ក.ន.ក ស្រុក ក្រុង តាមប្រព័ន្ធ Zoom ធ្វើនៅស្រុកទ្រាំង ស្រុកត្រាំកក់ និងក្រុងដូនកែវ។<br>-បើកវគ្គបណ្តុះបណ្តាលបំប៉នពង្រឹងសមត្ថភាពស្ត្រី ថ្នាក់ក្រុង/ស្រុក/ឃុំ/សង្កាត់ ក្រោមប្រធានបទ "ពង្រឹងយន្តការទប់ស្កាត់ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរ មនុស្ស និងទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់" នៅស្រុក សំរោង កោះអណ្តែត និងស្រុកដូនកែវ។ | ០៣<br><br>០៣ | ២០៩<br><br>១៧០ | ១៣៨<br><br>១៦៣ |
| **ខេត្តរតនគីរី៖** មន្ទីរកិច្ចការនារីខេត្ត បាន៖<br>-បើកវគ្គបណ្តុះបណ្តាលដល់ក្រុម GBV ស្រុក ស្តីពីបទដ្ឋានអប្បបរមានស្រាប់ផ្តល់ប្រឹក្សាយោបល់ជាមួយមូលដ្ឋានដល់ស្ត្រី និងក្មេង ស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅស្រុកលំផាត់ និងស្រុកកូនមុំ។<br>-មន្ទីរកិច្ចការនារីខេត្ត បានសហការជាមួយអង្គការវៃរ បើកវគ្គបណ្តុះបណ្តាល ស្តីអំពីកិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រី និងកុមារនៅកម្ពុជា។ | ០២<br><br>០១ | ៤៦<br><br>១៦ | ២៤<br><br>១០ |

| | | | |
|---|---|---|---|
| **ខេត្តកំពង់ចាម៖** មន្ទីរអប់រំ យុវជន និងកីឡា បើកវគ្គបណ្តុះបណ្តាល គ្រូកិច្ចសន្យាកម្មវិធីអក្ខរកម្ម ដែលមានភារកិច្ចចុះបង្រៀន ផ្សព្វផ្សាយអប់រំមេរៀន ស្តីពីច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋនៅស្រុកជើងព្រៃ។ | ០១ | ៣០ | ១៧ |
| **ខេត្តត្បូងឃ្មុំ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី បើវគ្គបណ្តុះបណ្តាលបំពេញបន្ថែម ស្តីពី «ការគ្រប់គ្រង និងការបញ្ជូនករណីជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅកាន់សេវាគាំទ្រ» ជូនដល់សមាជិកសមាជិកា នៃក្រុមជំនាញទាំង ០៦ សមាជិកលេខាធិការដ្ឋានថ្នាក់ខេត្ត និងអង្គការសង្គមស៊ីវិល។ | ០១ | ២០ | |
| **ខេត្តព្រៃវែង៖**<br>-មន្ទីរកិច្ចការនារីខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់អំពើហិង្សា និងកិច្ចការពារជនរងគ្រោះ ដល់សមាជិកក្រុមប្រឹក្សាឃុំ និងអ្នកទទួល បន្ទុកកិច្ចការនារី និងកុមារឃុំ។ | ០១ | ១៥ | ១៥ |
| -ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ តាមប្រព័ន្ធ Zoom ដល់ផែនប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងវរៈការពារព្រំដែន៦០៧។ | ០១ | ០៦ | ០២ |
| -លេខាធិការដ្ឋាន គ.ខ.ប.ជ សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារនិងស្ត្រី (LSCW) បើកវគ្គបណ្តុះបណ្តាល ស្តីពីការមិនបង្ករហានិភ័យ និងការគ្រប់គ្រងករណីសម្រាប់ពលករ នៅស្រុកកំពង់ត្របែក។ | ០១ | ៣០ | ១២ |
| **ខេត្តកោះកុង៖** បាន<br>-សហការជាមួយអង្គការ ASEAN-Acts បើកវគ្គបណ្តុះបណ្តាល ស្តីពី "**បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវា សមស្រប**" ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលមហោស្រពខេត្ត។ | ០១ | ៣៨ | ១០ |
| -សហការជាមួយអង្គការយូនីសេហ្វ បើកវគ្គបណ្តុះបណ្តាល ស្តីពី"**កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន**" ក្រោមអធិបតីភាពលោកជំទាវ វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលាខេត្តកោះកុង។ | ០១ | ៤១ | ២០ |
| **ខេត្តព្រះសីហនុ៖** ក្រុមការងារអន្តរជំនាញទទួលបានវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនិតិវិធីស៊ើបអង្កេត ករណីជួញដូរមនុស្សអំឡុងពេលកូវីដ-១៩ ។ | ០១ | ០៥ | ០១ |
| **ខេត្តកំពត៖** ស្នងការដ្ឋាននគរបាលខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការស៊ើបអង្កេត និងការឆ្លើយតបបទល្មើសផ្លូវភេទលើកុមារ។ | ០១ | ១៧ | |
| សរុប | ៦២ វគ្គ | ២.១១១ នាក់ | ៨៦៧នាក់ |

### ក.២. សិក្ខាសាលា

▪ ថ្នាក់ជាតិ

• ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានសហការជាមួយអង្គការវេតៈអ៊ីនធើណេសិនណល និងគម្រោងកម្មវិធី ASEAN-ACT រៀបចំសិក្ខាសាលាចំនួន ០២លើក ក្រោមអធិបតីភាពឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការក្រសួងស.អ.យ ដូចជាសិក្ខាសាលា៖

◦ ពិគ្រោះយោបល់ចុងក្រោយ លើការធ្វើបច្ចុប្បន្នភាពសារាចរណែនាំ ០០៩និងទម្រង់ គ្រប់គ្រងជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដោយមានការចូលរួមពីមន្ត្រីពាក់ព័ន្ធនៃក្រសួងស.អ.យ មន្ទីរស.អ.យ រាជធានី-ខេត្ត និងអង្គការដៃគូមិនមែនរដ្ឋាភិបាល សរុបចំនួន ១១០នាក់ (ស្រី ៣៧នាក់ )នៅសណ្ឋាគារ ប្រេស៊ីដង់ ខេត្តបាត់ដំបង។

◦ កែសម្រួលចុងក្រោយលើនីតិវិធី ស្តីពីដំណើរមាតុភូមិនិវត្តន៍ជនរងគ្រោះ និងជនសង្ស័យថារងគ្រោះ ដោយអំពើជួញដូរមនុស្ស ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពីក្រសួង ស្ថាប័ននាយកដ្ឋាន មន្ទីរ ស.អ.យ និងអង្គការដៃគូមិនមែនរដ្ឋាភិបាល សរុបចំនួន ៤៦នាក់ (ស្រី ១៣នាក់) នៅមន្ទីរ ស.យ.អ ខេត្តព្រះសីហនុ។

• អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំសិក្ខាសាលា ចំនួន ០២លើក៖

◦ សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការរៀបចំផែនការជាតិ សម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលរៀបចំដោយអង្គការ IOM សិក្ខាកាមចូលរួមចំនួន ៥៥នាក់ (ស្រី ១៦នាក់) នៅសណ្ឋាគារកាំបូឌីយ៉ាណា។

◦ សិក្ខាសាលា កិច្ចប្រជុំពិនិត្យពិភាក្សា លើកទី២ និងធ្វើបច្ចុប្បន្នភាពសៀវភៅគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប សិក្ខាកាមចូលរួមចំនួន ៥២នាក់ (ស្រី ០៨នាក់) ដោយមានកិច្ចសហការគាំទ្រពីអង្គការ Asian ACT នៅសណ្ឋាគារស៊ាន់វ៉េភ្នំពេញ។

• អង្គការ We World បានសហការជាមួយ ក្រុមការងារលេខាធិការដ្ឋាន ក្រុមការងារកិច្ចការអនុវត្តច្បាប់ និងក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ ខេត្តសៀមរាប៖ រៀបចំសិក្ខាសាលាបិទបញ្ចប់គម្រោងសិទ្ធិការងារ "លើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ" បានចំនួន ០១លើក នៅរាជធានីភ្នំពេញ។

▪ ថ្នាក់ក្រោមជាតិ

• ខេត្តស្វាយរៀង៖ ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការហាកា (HAGAR) បើកសិក្ខាសាលា ស្តីពីសិទ្ធិកុមារ និងច្បាប់នានាពាក់ពន្ធ័នឹងកិច្ចការពារកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការជួញដូរមនុស្ស ០១លើក មានសិក្ខាកាម ៥៤នាក់(ស្រី៣៧នាក់)។

• បាត់ដំបង៖ សហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងអង្គការ ASEAN-ACT រៀបចំសិក្ខាសាលាស្តីពី កិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ០១លើក នៅស្រុកសំពៅលូន មានសិក្ខាកាម ៧៤នាក់ ស្រី ៤២នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំក្នុងប្រទេស និងក្រៅប្រទេស

ខ.១.១.កិច្ចប្រជុំក្នុងប្រទេស

▪ ថ្នាក់ជាតិ

• គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ

-លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បាន អញ្ជើញដឹកនាំកិច្ចប្រជុំ ៖

○ពិនិត្យពិភាក្សា កែសម្រួលខ្លឹមសាររបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២ របស់គ.ជ.ប.ជ ចំនួន ០២លើក នៅសាលប្រជុំគ.ជ.ប.ជ។

○ពាក់ព័ន្ធការធ្វើបច្ចុប្បន្នភាពលើ គោលការណ៍ណែនាំ ស្ដីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប។

○បានបើកកិច្ចប្រជុំពិនិត្យ ពិភាក្សាអំពីផែនការសកម្មភាពដែលត្រូវអនុវត្ត ដោយអង្គការដៃគូ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ និងទិសដៅបន្ត មានអ្នកចូលរួម ១៨រូប (ស្រី០៨រូប)។

○ស្ដីពីការធ្វើបទបង្ហាញពីសេវាកម្ម និងព័ត៌មាន នៃគំពេងមជ្ឈមណ្ឌល CASA ដែលស្នើឡើងដោយអង្គភាពការពារកុមារ CPU អ្នកចូលរួមចំនួន ១៧នាក់ (ស្រី ០៣នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។

○តាមប្រព័ន្ធវីដេអូអនឡាញ ស្ដីពីការត្រៀមសម្រាប់កិច្ចប្រជុំទ្វេភាគី រវាង រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលថៃ នៅសាលប្រជុំ គ.ជ.ប.ជ។

○តាមប្រព័ន្ធវីដេអូអនឡាញ ស្ដីពីយុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិត "**រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ**" នៅសាលប្រជុំ គ.ជ.ប.ជ។

-លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖

○បើកកិច្ចប្រជុំប្រចាំខែ ស្ដីពីវឌ្ឍនភាពការងារ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

○បានបើកកិច្ចប្រជុំត្រួតពិនិត្យបច្ចុប្បន្នភាព និងការបំពេញសាលាកប័ត្រព័ត៌មាននគរបាលជាតិ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។

-**ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ** បានសហការជាមួយ **ក្រសួងអប់រំ យុវជន និងកីឡា** និងអង្គការ **Cambodia Acts** បើកកិច្ចប្រជុំពិភាក្សា ស្ដីពី «គម្រោងអភិវឌ្ឍសមត្ថភាពភាសាបរទេស (ខ្មែរ-ថៃ) និងការចុះក្នុងតំបន់ ដើម្បីសួរសុខទុក្ខការអនុវត្តន៍គម្រោងនៅតាមសាលារៀនក្នុងខេត្តកោះកុង» ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលអ្នកចូលរួមសរុប ៣៤នាក់ (ស្រី០៩នាក់)។

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានរៀបចំកិច្ចប្រជុំ៖

○លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២ ជាមួយក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារការពារជនរងគ្រោះ អង្គការដៃគូ ពាក់ព័ន្ធ ចំនួន ០២លើក នៅទីស្ដីការក្រសួងស.អ.យ។

○ក្រុមការងារបច្ចេកទេសជាមួយភាគីថៃ ស្ដីពីការពិភាក្សាលើការងារសាងសង់មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនងាយរងគ្រោះផ្សេងទៀត នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួម ០៨នាក់(ស្រី ០៧នាក់)។

▪ **ថ្នាក់ក្រោមជាតិ**

- **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុកក្រុង ស្រុក បានរៀបចំកិច្ចប្រជុំ៖

○បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២១ និងទិសដៅឆ្នាំ២០២២ ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានចិន្ត្រៃយ៍ គ.ជ.ប.ជ និងឯកឧត្តម **អ៊ាន យុន** ប្រធានក្រុមប្រឹក្សាខេត្ត មានអ្នកចូលរួមសរុប ២០០នាក់ ស្រី ៦២នាក់។

- ត្រួតពិនិត្យបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែកុម្ភៈ ឆ្នាំ២០២២ បានចំនួន **០១**លើក ដែលមានអ្នកចូលរួមសរុប **៧៦**នាក់ ស្រី **៣៦**នាក់ តាមប្រព័ន្ធបញ្ជូនរូបភាព ZOOM។
- ត្រួតពិនិត្យការងារត្រៀមរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅបន្តឆ្នាំ ២០២២ បានចំនួន០១លើក ដែលមានអ្នកចូលរួមសរុប **២០**នាក់ ស្រី ០៩នាក់ នៅបន្ទប់ប្រជុំលេខ១ សាលាខេត្ត។
- ប្រចាំខែ ស្ដីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២២ បានចំនួន**១២**លើក ដែលមាន អ្នកចូលរួមសរុប **៣៤៧** នាក់ ស្រី **១១១**នាក់។

- **ខេត្តបន្ទាយមានជ័យ៖** បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារ បានចំនួន **០១**លើក មានអ្នកចូលរួមចំនួន **១៥**នាក់(ស្រី **១០**នាក់)។
- **ខេត្តព្រះវិហារ៖** លេខាធិការដ្ឋានគ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំត្រីមាសទី១ ឆ្នាំ២០២២ បានចំនួន **០១**លើក អ្នកចូលរួម **៣១**នាក់ ស្រី **១០**នាក់។
- **ខេត្តក្រចេះ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ប្រចាំឆ្នាំ២០២១ និងទិសដៅអនុវត្តបន្តឆ្នាំ២០២២ (តាមរយៈបណ្ដាញZoom Meeting) សមាសភាពចូលរួមសរុបចំនួន **៣០**នាក់ ស្រី **២១**នាក់។
- **ខេត្តកណ្ដាល៖**
  - ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្សប្រចាំខែមករា និងប្រចាំត្រីមាសទី១ ឆ្នាំ២០២២ និងលើកទិសដៅបន្តឆ្នាំ២០២៣ បានចំនួន **០៣**លើក មានអ្នកចូលរួមចំនួន **១១០**នាក់(ស្រី **៦៥**នាក់)។
  - ក្រុមការងារក្រុង-ស្រុក បានរៀបចំប្រជុំប្រចាំខែ បានចំនួន **១៣**លើក មានអ្នកចូលរួមចំនួន **៤៩៦**នាក់ (ស្រី **២៤៩**នាក់)។
- **ខេត្តស្វាយរៀង៖** គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ ស្ដីពីវឌ្ឍនភាពការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំឆ្នាំ២០២១ និងទិសដៅបន្តឆ្នាំ២០២២ ក្នុងបរិបទកូវីដ-១៩ ក្រោមអធិបតីភាពលោកជំទាវ **ឯក សុវណ្ណភារៈ** អភិបាលរងខេត្ត និងជាអនុប្រធាន អចិន្ត្រៃយ៍ គ.ខ.ប.ជ និងមានការអញ្ជើញចូលរួម ពីលោកស្រីស្នងការរងនគរបាលខេត្ត លោកមេ បញ្ជាការរង កងរាជអាវុធហត្ថខេត្ត លោកមេបញ្ជាការរងតំបន់ប្រតិបត្តិការសឹករងខេត្ត លោក លោកស្រី អភិបាល អភិបាល រងក្រុង ស្រុក ទាំង០៨ លោក លោកស្រីប្រធានអនុប្រធានមន្ទីរ-អង្គភាពជំនាញ ពាក់ព័ន្ធ នៃក្រុមការងារទាំង៦ ដែលមានវត្តមានចូលរួមចំនួន **៥៧**នាក់ស្រី **២៧**នាក់ ។
- **ខេត្តព្រៃវែង៖**
  - ឯកឧត្តម **ជា សុមេធី** ប្រធានគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស គ.ខ.ប.ជ បាន ដឹកនាំកិច្ចប្រជុំណែនាំដល់មន្ត្រីថ្នាក់ក្រុង/ស្រុក ធ្វើការផ្សព្វផ្សាយ ស្ដីពីច្បាប់ការប្រយុទ្ធប្រឆាំងនឹង អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងពំពើពរពោះជំនួសដល់ប្រជា ពលរដ្ឋបានយល់ដឹង និងកុំឱ្យចាញ់បោកពួកជនឆ្លៀតឱកាសមួយចំនួន បានចំនួន០៤លើកតាមប្រព័ន្ធ អនឡាញ។
  - លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានដឹកនាំក្រុមការងាររៀបចំកិច្ចប្រជុំត្រួតពិនិត្យការងារប្រចាំខែមករា កុម្ភៈ និងបូកសរុបរបាយការណ៍ប្រចាំត្រីមាសទី១ ឆ្នាំ២០២២ និងលើកទិសដៅបន្តត្រីមាសទី២ ដែល មានការចូលរួមពីក្រុមការងារទាំង៦ លេខាធិការដ្ឋាន អភិបាលរងក្រុង/ស្រុក និងអង្គការដៃគូ ប្រជុំ

ដោយផ្ទាល់បានចំនួន ០៤លើក និងតាមប្រព័ន្ធ Zoom ចំនួន ០១លើក មានសរុបចំនួន **១៧៧**នាក់ (ស្រី **៧០**នាក់)។

- **ខេត្តកំពត៖**
  - លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែ បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងការបំពេញកម្រងសំណួរសម្រាប់វាយតម្លៃការងារឆ្នាំ២០២២ មានអ្នកចូលរួម **២០**នាក់ ស្រី**១០**នាក់។
  - **ក្រុមការងារ គ ក ស ក ១១ឃុំ** ស្រុកដងទង់ បានរៀបចំកិច្ចប្រជុំ ផ្សព្វផ្សាយ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បានចំនួន **១១**លើក អ្នកចូលរួម **៤០៥**នាក់ ស្រី **២៧២**នាក់
  - **ក្រុមការងារ គ ក ស ក ១៨ឃុំ** ស្រុកឈូក បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បានចំនួន **១៨**លើក អ្នកចូលរួម **៣៤០**នាក់ ស្រី **២១៧**នាក់ ។
  - **ក្រុមការងារ គ ក ស ក** និងគ ក ន ក ឃុំ ស្រុកអង្គរជ័យ ផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស បានចំនួន ០១លើក អ្នកចូលរួម **៥៧**នាក់ ស្រី **៣៦**នាក់។
- **ខេត្តកែប៖** លោកជំទាវ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ រៀបចំកិច្ចប្រជុំដើម្បីណែនាំដល់មន្ទីរ អង្គភាពពាក់ព័ន្ធ រៀបចំផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចំនួន ០១លើក ។
- **ខេត្តកំពង់ឆ្នាំង៖**
  - លោកជំទាវប្រធានលេខាធិការដ្ឋានខេត្ត បានដឹកនាំកិច្ចប្រជុំប្រចាំខែមករា កុម្ភៈ និងខែមីនា ឆ្នាំ២០២២ បានចំនួន **០៣**លើក តាមប្រព័ន្ធអនឡាញ។
  - ក្រុមការងារស្រុករលាប្អៀរ បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ស្រុក ០១លើក អ្នកចូលរួម ២០នាក់(ស្រី ១៩នាក់)។

## ខ.៣. ជំនួបពិភាក្សាការងារ

- **ថ្នាក់ជាតិ**
- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ**
  - លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖
    - ទទួលជួបពិភាក្សាការងារជាមួយ លោក **សុខ លាំង** អ្នកស្រាវជ្រាវឯករាជ្យ នៃវិទ្យាស្ថានឯករាជ្យក្រៅប្រទេស (ODI) ដែលមានទីតាំងនៅទីក្រុងឡុងប្រទេសអង់គ្លេស និងជាអ្នកសិក្សាស្រាវជ្រាវឱ្យកម្មវិធី ASEAN-ACT ចូលជួបសម្តែងការគួរសម និងអនុញ្ញាតឱ្យសួរសំណួរស្រាវជ្រាវមួយចំនួន ពាក់ព័ន្ធភាពងាយរងគ្រោះដោយអំពើជួញដូរមនុស្សរបស់ពលករចំណាកស្រុកកម្ពុជានៅក្នុងបន្ទប់ការងាររបស់ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ។
    - ទទួលជួបពិភាក្សាការងារជាមួយលេខាស្ថានទូតអាមេរិក ពាក់ព័ន្ធនឹងករណីពពោះជំនួស។
    - ទទួលជួបសម្តែងការគួរសម ជាមួយតំណាងអង្គការ UNICEF Mr. Benjamin, Wildfire Child Protection Specialist និង លោកស្រី **ចាន់ កញ្ញា** មន្ត្រីអភិវឌ្ឍន៍យុវជននិងវ័យជំទង់ ដើម្បីពិភាក្សាពីការពង្រីកកិច្ចសហការលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសកិច្ចការពារកុមារជាជនរងគ្រោះ ងាយរងគ្រោះ និងការពង្រឹងក្រមសីលធម៌របស់មន្ត្រីនៅមណ្ឌលចត្តាឡីស័ក ក៏ដូចជាមន្ត្រីពាក់ព័ន្ធការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ នៅក្នុងចំណោមពលករទេសន្តរប្រវេសន៍ ផ្តោតសំខាន់ស្ត្រីនិងកុមារ។

- ជួបពិភាក្សាការងារ ជាមួយតំណាងអង្គការ JICA ប្រចាំនៅកម្ពុជា ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ០១លើក។
- ជួបពិភាក្សាការងារជាមួយប្រធានតំណាងអង្គការវីនរ៉ក់ ស្តីអំពីកិច្ចសហប្រតិបត្តិការការងារប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស ០១លើក។
- ជំនួបជាមួយតំណាងម្ចាស់ជំនួយនៃអង្គការ ការីតាសស្វីស ដើម្បីសំណេះសំណាល និងស្វែងយល់ពីបច្ចុប្បន្នភាពនៃការអនុវត្តគម្រោងរបស់ខ្លួន ០១លើក។

• **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាន៖

- ទទួលជួបសម្ភាសន៍ជាមួយ អង្គការ UNDP អំពីការសិក្សាស្តីពីការបង្កើនលំហូរផ្ទេរប្រាក់ឆ្លងដែន ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១០ខែ មករា ឆ្នាំ២០២២ តាមប្រព័ន្ធ Zoom។
- ចូលរួមពិភាក្សាការងារជាមួយអង្គការ IOM ពាក់ព័ន្ធនឹងការងារជួញដូរមនុស្ស ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២។

▪ **ថ្នាក់ក្រោមជាតិ**

• **ខេត្តសៀមរាប** លេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមការងារទេសន្តរប្រវេសន៍ និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុកពួក បានទទួលប្រជុំពិភាក្សាការងារ៖

- និងផ្តល់កិច្ចសម្ភាសន៍ជាមួយក្រុមអ្នកស្រាវជ្រាវវាយតម្លៃរបស់ IJM ស្តីពីកិច្ចសហការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរកម្លាំងពលកម្ម ចំនួន ០១លើក នៅរដ្ឋបាលសាលាខេត្ត។
- ជាមួយអង្គការមូលនិធិA21 ស្តីពីការអនុវត្តផែនការសកម្មភាពឆ្នាំ២០២២ លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០១លើក នៅរដ្ឋបាលសាលាខេត្ត។
- លើការអនុវត្តគម្រោងកិច្ចការពារជំនាន់ថ្មី ឬ Protection Plus ជាមួយអង្គការភ្លែនអន្តរជាតិ អង្គការសកម្មភាពដើម្បីកុមារ (APLE) អង្គការTPO អង្គការជំហានដំបូង និងអង្គការបណ្តាញសេវាទូរស័ព្ទកម្ពុជា ចំនួន ០១លើក តាមប្រព័ន្ធ Zoom។
- ជាមួយអង្គការជីវិតនៅកម្ពុជា អំពីការត្រៀមរៀបចំវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាព ស្តីពីវិធានការបង្វែរអនីតិជនជំទាស់នឹងច្បាប់ ចំនួន ០១លើក តាមប្រព័ន្ធ Zoom។
- ជាមួយអ្នកវាយតម្លៃគម្រោង ស្តីពីលើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ ដែលអនុវត្តដោយអង្គការ We World ចំនួន ០១លើក នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។
- និងផ្តល់បទសម្ភាសន៍នៃការស្រាវជ្រាវ ស្តីពីការជួញដូរមនុស្សប្រទេសនៅក្នុងតំបន់មេគង្គប្រទេសកម្ពុជា ថៃ ឡាវ និងប្រទេសវៀតណាម(TIP) របស់គម្រោង JICA
- ជាមួយអ្នកវាយតម្លៃគម្រោងស្តីពី លើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ ដែលអនុវត្តដោយអង្គការ We World។

• **ខេត្តបន្ទាយមានជ័យ៖**

- លេខាធិការដ្ឋាន គ.ជ.ប.ជ បានផ្តល់បទសម្ភាសជាមួយក្រុមការងាររបស់ ក្រុមហ៊ុន RESEARCH និង Communication Group (RCG) សហការជាមួយអង្គការ IJM ដែលគោលបំណងនៃការជួបសម្ភាសន៍មានពីរ៖ ១-សិក្សាស្វែងយល់ពីបទពិសោធន៍នៃដំណើររឿងក្តី និងការងារប្រយុទ្ធប្រឆាំងលើបទល្មើសជួញដូរពលកម្មក្នុងស្រុក និងឆ្លងដែន។ ២-ស្នើសុំមតិយោបល់ពីភាពខ្វះចន្លោះនៃការងារប្រយុទ្ធប្រឆាំងបទល្មើសខាងលើ និងអនុសាសន៍អំពីការធ្វើអោយប្រសើរឡើងនូវការងាររឿងក្តី ក៏ដូចជានីតិវិធីក្នុងកិច្ចសហការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរពលកម្ម ជាមួយស្ថាប័នពាក់ព័ន្ធនានា។

- លោក **ណាង វុទ្ធី** អនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយ អង្គការ JICA ស្តីពីគម្រោងពង្រឹងបណ្តាញក្នុងតំបន់សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមតំបន់មេគង្គ(២០២១-២០២៤)។

• **ខេត្តស្វាយរៀង៖** លោកជំទាវ **ឯក សុវណ្ណភារៈ** អភិបាលរង និងជាអនុប្រធានចិន្ត្រៃយ៍គ.ខ.ប.ជ បាន៖
  - ជួបប្រជុំពិភាក្សាការងារ ជាមួយក្រុមការងារស្ថានទូតសហរដ្ឋអាមេរិក លោក **ចូណាថាន អាដាម** ប្រធានផ្នែកនយោបាយ និងលោក ស៊ុយ ហ៊ាមខេមរា អ្នកជំនាញនយោបាយ ពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងពលកម្មកុមារ។
  - ប្រជុំពិភាក្សាការងារជាមួយអង្គការជំនួយផ្លូវច្បាប់ ដល់កុមារ និងស្ត្រី ពាក់ព័ន្ធការអនុវត្តគម្រោង "ការពង្រឹងសិទ្ធិទទួលបានការអប់រំ និងការងារ តាមរយៈការចូលរួមរបស់សហគមន៍ ក្នុងគោលបំណង ដើម្បីចូលរួមទប់ស្កាត់អំពើជួញដូរមនុស្ស និងផ្តល់សេវាគាំទ្រសម្រាប់ពលករ។

• **ខេត្តតាកែវ៖** លោកស្រីអនុប្រធានចិន្ត្រៃយ៍គ.ខ.ប.ជ បានជួបពិភាក្សាការងារជាមួយលោកជំទាវ **ទូច សារ៉ុម** រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា ស្តីពីការបញ្ជ្រាបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងពុទ្ធចក្រ និងអាណាចក្រ នៅសាលប្រជុំក្រសួងកិច្ចការនារី។

### គ. ការខារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេស គឺ **២៤៤**លើក មានអ្នកចូលរួមសរុប **១.០៤៩**នាក់ (ស្រី **៥៤០**នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន **១២២**លើក ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន **២២**លើលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា **៣០**លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន **៧០**លើក។(**ឧបសម្ព័ន្ធ១**)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។

- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**ខ. ចំណុចខ្វះខាត ឬភាពប្រឈម**

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ថ្វីត្បិតតែមានយន្តការក្នុងកិច្ចសហប្រតិបត្តិការគ្នា តែកិច្ចសហការមួយចំនួននៅមិនទាន់បានល្អនៅឡើយ។
- មន្ត្រីទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមួយចំនួន មានការផ្លាស់ប្តូរ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំង និងរំលេចឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

**គ. សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាសឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយ...

អ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅអនុវត្តបន្តត្រីមាសទី២ ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

### ក.ការងារច្បាប់ គោលនយោបាយ និងកិច្ចសហប្រតិបត្តិការ

ក.១. បន្តរៀបចំគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលជាតម្រូវការចាំបាច់សម្រាប់បម្រើ ដល់ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ។

ក.២. ធ្វើបច្ចុប្បន្នភាពសៀវភៅ គោលការណ៍ណែនាំស្តីពី បែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

ក.៣. គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ និងក្រសួងកិច្ចការនារី ដើម្បីបន្តពិគ្រោះយោបល់ និងពិនិត្យឡើងវិញខ្លឹមសារសេចក្តីព្រាងច្បាប់ ស្តីពីអំពើពោះជំនួស។

ក.៤. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសកិច្ចសហការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសពាក់ព័ន្ធ ។

ក.៥. បន្តជំរុញការអនុវត្តអនុស្សរណៈ និងកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេស និងដៃគូពាក់ព័ន្ធដែលបានចុះហត្ថលេខារួចហើយ ដើម្បីបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផល។

ក.៦. ត្រៀមចុះហត្ថលេខាលើស្តង់ដានៃនីតិវិធីប្រតិបត្តិ ស្តីពីកិច្ចសហការក្នុងការអនុវត្តច្បាប់ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស នៃព្រះរាជាណាចក្រថៃ។

ក.៧. ត្រៀមប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការគោលនយោបាយជាតិ ស្តីពីសុខភាពជនទេសន្តរប្រវេសន៍ របស់ក្រសួងសុខាភិបាល។

ក.៨. រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ដើម្បីកសាងបទដ្ឋានគតិយុត្តិនានា សម្រាប់ការពារសិទ្ធិ សុវត្ថិភាព ផលប្រយោជន៍ និងសេចក្តីថ្លៃថ្នូររបស់ពលករទេសន្តរប្រវេសន៍ក្នុងវិស័យនេសាទសមុទ្រ។

ក.៩. ត្រៀមកិច្ចប្រជុំបួនប្រទេស កម្ពុជា ឡាវ វៀតណាម មីយ៉ាន់ម៉ា ក្នុងការពង្រឹងកិច្ចសហការ ការពារ និងបង្ការ ទប់ស្កាត់ ការនាំមនុស្សឆ្លងដែនខុសច្បាប់ ជាពិសេសស្ត្រី និងកុមារ ក៏ដូចជាទារក។

ក.១០.ត្រៀមបន្តចុះហត្ថលេខាអនុស្សរណៈ/កិច្ចព្រមព្រៀងសហប្រតិបត្តិការ ជាមួយដៃគូពាក់ព័ន្ធ។

ក.១១.បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ដើម្បីពង្រឹងការអនុវត្តវិធានការច្បាប់ វិធានការបង្ការ ទប់ស្កាត់ និងវិធានការសង្គ្រោះ និងការពារជនរងគ្រោះ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

ក.១២.បន្តពង្រឹងយន្តការដឹកនាំបញ្ជាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពទាំងលើការងារផ្សព្វផ្សាយអប់រំ និងការចាត់តាំងអនុវត្តច្បាប់ ព្រមទាំងជំរុញការតាមដានត្រួតពិនិត្យ និងកែលម្អជាប្រចាំចំពោះកិច្ចប្រតិបត្តិការរបស់មន្ត្រីអនុវត្តច្បាប់ សំដៅជំរុញឱ្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សកាន់តែទទួលបានប្រសិទ្ធផលខ្ពស់ ។

### ខ. ការងារបង្ការ ទប់ស្កាត់

ខ.១. បន្តសហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំយុទ្ធនាការ «គាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត និងលើកកម្ពស់សីលធម៌ ដើម្បីសុវត្ថិភាពសង្គម»។

៤.២. សហការជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) រៀបចំសិក្ខាសាលាច្រកចេញចូលតែមួយ ស្តីពី «សេវាកម្មកុមារ»។

៤.៣. ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រសួង ស្ថាប័ន និងដៃគូពាក់ព័ន្ធ បន្តបើកវគ្គបណ្តុះបណ្តាលសៀវភៅសិក្សាអប់រំស្តីពី «ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន» ដល់គ្រូឧទ្ទេសក៍ថ្នាក់ជាតិ គ្រូឧទ្ទេសក៍គរុកោសល្យភូមិភាគ និងគ្រូបង្គោល តាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ នៅទូទាំងប្រទេស និងតាមដានការអនុវត្តកម្មវិធីសិក្សាគ្រប់កម្រិតខាងលើ។

៤.៤. សហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជា(TRC) ផ្ញើការផ្សព្វផ្សាយសារអប់រំ ដល់ប្រជាពលរដ្ឋតាមរយៈទូរស័ព្ទចល័ត នៅថ្ងៃទិវាជាតិពាក់ព័ន្ធ។

៤.៥. អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដើម្បីជំរុញ និងពង្រីកការផ្សព្វផ្សាយអំពីឱកាសការងារឱ្យកាន់តែទូលំទូលាយនៅតាមសហគមន៍ ជាពិសេសសហគមន៍ដែលងាយរងគ្រោះ រួមទាំងពលករទេសន្តប្រវេសន៍ដែលវិលត្រឡប់។

៤.៦. សហការជាមួយ រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតនីតិវិធីងាយស្រួលក្នុងការផ្សារភ្ជាប់ទំនាក់ទំនង និងការទទួលបានការប្រឹក្សាយោបល់ពីទីភ្នាក់ងារជាតិមុខរបរ និងការងារ និងក្រសួង ស្ថាប័នពាក់ព័ន្ធ អំពីជម្រើសការងារ ឬមុខរបរ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេសផ្សេងៗសម្រាប់ក្រុមជនងាយរងគ្រោះ ជាពិសេស ពលករទេសន្តប្រវេសន៍ដែលវិលត្រឡប់ពីបរទេស។

៤.៧. បន្តជំរុញការគ្រប់គ្រង និងធ្វើអធិការកិច្ចទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីធានាការអនុវត្តគោលនយោបាយ និងច្បាប់ពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវរបស់ទីភ្នាក់ងារ ក្នុងការការពារសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដល់ពលករក្នុងការធ្វើទេសន្តប្រវេសន៍ការងារ។

៤.៨. បន្តរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ និងវេទិកាជាតិអន្តរសាសនានៅកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៤.៩. បន្តសហការជាមួយអង្គការសហប្រជាជាតិ (IOM, WHO, UNFPA, UNICEF) និងដៃគូផ្សេងៗទៀត ដើម្បីរៀបចំកម្មវិធី ឆ្លើយតបទៅនឹងផលប៉ះពាល់លើសុខភាព និងជីវភាពពលករទេសន្តប្រវេសន៍ និងគ្រួសារ ក្នុងស្ថានភាពនៃការរាតត្បាតដោយជំងឺកូវីដ-១៩ និងគ្រោះមហន្តរាយផ្សេងៗទៀត។

៤.១០.បន្តចូលរួមយ៉ាងសកម្មក្នុងការអនុវត្ត គោលនយោបាយ ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ការផ្សព្វផ្សាយអំពីការបង្ការ ទប់ស្កាត់ ការឆ្លង និងចម្លងជំងឺកូវីដ-១៩ និងផលប៉ះពាល់ ព្រមទាំងចុះតាមដានការអនុវត្តគោលនយោបាយនានារបស់រាជរដ្ឋាភិបាល នៅថ្នាក់ក្រោមជាតិ។

៤.១១. បន្តលើកកម្ពស់ការងារផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងពង្រីកការអប់រំតាមគ្រប់រូបភាព ដើម្បីលើកកម្ពស់ការយល់ដឹងឱ្យបានទូលំទូលាយ អំពីរាល់ទម្រង់នៃអំពើជួញដូរមនុស្ស ទំនាក់ទំនងរវាងទេសន្តប្រវេសន៍និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងនិងក្រៅសាលារៀន និងជនងាយរងគ្រោះដទៃទៀត។

៤.១២.បង្កើនការចុះធ្វើអធិការកិច្ច ជាពិសេស អធិការកិច្ចដោយមិនជូនដំណឹងជាមុន ដើម្បីកំណត់រកអំពើកេងប្រវ័ញ្ចផ្សេងៗ និងមានវិធានការក្នុងប្រភេទការងារដែលមានភាពរងគ្រោះខ្ពស់ ដូចជានៅតាមទីភ្នាក់ងារជ្រើសរើសពលករឯកជន រោងចក្រសហគ្រាស សហគ្រាសឡឥដ្ឋ កសិដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ កន្លែងសេវាកម្សាន្ត ជាដើម។

៤.១៣.លើកកម្ពស់ការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករ និងការអនុវត្តក្រមសីលធម៌ របស់ទីភ្នាក់ងារ និងកាត់បន្ថយការយកថ្លៃឈ្នួលពីពលករ ក្នុងនីតិវិធីនៃការជ្រើសរើសពលករទេសន្តប្រវេសន៍។

៤.១៤.បន្ត និងជំរុញរៀបចំផែនការអនុវត្តគោលបំណងអាទិភាព GCM និងអនុសញ្ញាអាស៊ាន។

## គ. ការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ

គ.១.បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ និងមន្ត្រីជួរមុខក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

គ.២.បន្តស៊ើបអង្កេត ស្រាវជ្រាវ បង្ក្រាប និងផ្តន្ទាទោស បទល្មើសពាក់ព័ន្ធអំពើជួញដូរមនុស្ស។

គ.៣.បន្តពង្រឹងកិច្ចសហការរវាងមន្ត្រីនគរបាលយុត្តិធម៌ និងស្ថាប័នអយ្យការ ក្នុងការអនុវត្តនីតិវិធីស៊ើបអង្កេត ប្រមូលភស្តុតាង ដើម្បីដាក់បន្ទុកជនល្មើសជួញដូរមនុស្ស។

គ.៤.បន្តពង្រឹងកិច្ចសហការជាមួយសមត្ថកិច្ចប្រទេសពាក់ព័ន្ធ ដើម្បីជំរុញការងារអនុវត្តច្បាប់ និងយុត្តិធម៌ព្រហ្មទណ្ឌ ក្នុងការបង្ក្រាបបទល្មើសជួញដូរមនុស្សឆ្លងដែន។

គ.៥.ជំរុញការអនុវត្តនីតិវិធី នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

## ឃ. ការងារការពារជនរងគ្រោះ

ឃ.១.ពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យពលករ នៅក្នុងវដ្តនៃទេសន្តរប្រវេសន៍ ដើម្បីធ្វើជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយ និងវិធានការសម្រាប់ការគ្រប់គ្រងលំហូរទេសន្តរប្រវេសន៍ ជាពិសេស ដើម្បីផ្តល់សេវាជូនពលករដែលត្រូវបានបញ្ជូនត្រឡប់ដោយអាជ្ញាធរបរទេស និងពលករដែលវិលត្រឡប់ពីប្រទេសគោលដៅតាមច្រកព្រំដែនសំខាន់ៗ។

ឃ.២.បន្តពង្រឹងយន្តការសម្រាប់ការទទួលពលករ ការគ្រប់គ្រង និងដំណើរការមណ្ឌលទទួលពលករ កំរៀង ខេត្តបាត់ដំបង ដោយមានកិច្ចសហការពីបណ្តាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការដៃគូក្នុងការផ្តល់សេវា។

ឃ.៣.រៀបចំសិក្ខាសាលាថ្នាក់ជាតិ ស្តីពីកិច្ចការពារកុមារ ក្នុងទេសន្តរប្រវេសន៍ ពីអំពើជួញដូរមនុស្ស និងការរំលោភបំពាន ។

ឃ.៤.ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បន្តរៀបចំវគ្គបណ្តុះបណ្តាលៈ
- គោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស។
- គោលការណ៍ណែនាំស្តីពី «បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប» ដល់មន្ត្រីជួរមុខ។

ឃ.៥.ធ្វើបច្ចុប្បន្នភាពលើនីតិវិធីប្រតិបត្តិបទដ្ឋាន(SOPs) ស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយ សារការជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

ឃ.៦.បន្តកិច្ចសហប្រតិបត្តិការជាមួយៈ
- ក្រសួងយុត្តិធម៌ ដើម្បីរៀបចំឱ្យមានមន្ត្រីសង្គមកិច្ចចូលរួមក្នុងប្រព័ន្ធតុលាការ នៅតាមសាលាដំបូង រាជធានី ខេត្ត។
- ក្រសួងសុខាភិបាល ក្នុងការជួយដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលបានសេវាពិនិត្យសុខភាព និងការព្យាបាលដោយឥតគិតថ្លៃ នៅតាមមជ្ឈមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋ។
- ស្ថានទូត និងកុងស៊ុល នៅក្រៅប្រទេស(តាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) ដើម្បីជួយដល់ជនរងគ្រោះ និងសម្រួលដល់ដំណើរការមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជា ឱ្យបានឆាប់រហ័ស និងមានសុវត្ថិភាព។
- មន្ត្រីថ្នាក់ក្រោមជាតិ ក្នុងដំណើរការស្វែងរក ប៉ាន់ប្រមាណគ្រួសារ តាមដាន សមាហរណកម្ម និងបិទករណីរបស់ជនរងគ្រោះ។
- ភាគីថៃ ដែលកំពុងដំណើរការឯកសារ ដើម្បីកសាងមជ្ឈមណ្ឌលស្តារនីតិសម្បទាជនរងគ្រោះ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

ឃ.៧.បន្តចុះអធិការកិច្ចមជ្ឈមណ្ឌលរបស់អង្គការដែលបានចុះកិច្ចព្រមព្រៀងជាមួយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

ឃ.៨.ពិនិត្យលទ្ធភាព ដើម្បីបង្កើតមជ្ឈមណ្ឌលស្ដារនីតិសម្បទាជនរងគ្រោះជារបស់រដ្ឋ។

ឃ.៩.គាំទ្រក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការបណ្ដុះបណ្ដាលមន្ត្រីពាក់ព័ន្ធនៅក្នុងស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសគោលដៅ អំពីគោលការណ៍ណែនាំ ស្ដីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប។

ឃ.១០.រៀបចំឧបករណ៍វាយតម្លៃអំពីភាពប្រឈម នៃមេរៀន ស្ដីពី«ការអនុវត្តនីតិវិធីនៃការកំណត់អត្តសញ្ញាណបឋមជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្ដល់សេវាសមស្រប» ក្នុងខេត្តដែលបានបណ្ដុះបណ្ដាលរួចហើយ ។

ឃ.១១.រៀបចំយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃការផ្ដល់សេវាដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតាមមណ្ឌល និងនៅតាមសហគមន៍។

## ង. ការពង្រឹងសមត្ថភាព និងការតាមដានត្រួតពិនិត្យ

ង.១.ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធ ដល់មន្ត្រីទទួលបន្ទុកអនុវត្តថ្នាក់ក្រោមជាតិ លើការងារលេខាធិការដ្ឋាន ការងាររបាយការណ៍ ការកសាងផែនការ និងការងារត្រួតពិនិត្យ វាយតម្លៃ។

ង.២.បន្តធ្វើការប៉ាន់ប្រមាណ និងវាយតម្លៃពាក់កណ្ដាលអាណត្តិ ទៅលើការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ៥ឆ្នាំ(២០១៩-២០២៣) ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ង.៣.អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ គាំទ្រ និងសហការជាមួយក្រសួងយុត្តិធម៌ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីរៀបចំយន្តការប្រមូលទិន្នន័យថ្នាក់ជាតិ ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ជាពិសេសទិន្នន័យនៃការអនុវត្តច្បាប់ ការផ្ដន្ទាទោស និងការងារការពារជនរងគ្រោះឲ្យមានសង្គតិភាព។

ង.៤.គាំទ្រពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធនឹងការងារគ្រប់គ្រង គ្រប់ផ្នែក ដល់មន្ត្រីជំនាញក្នុងក្រុមការងារ និងលេខាធិការដ្ឋានរាជធានី ខេត្ត ដើម្បីពង្រឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ង.៥.បន្តធ្វើសេចក្ដីសម្រេចកែសម្រួលសមាសភាពក្រុមការងារអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការរាជធានី ខេត្ត។

ង.៦.រៀបចំប្រព័ន្ធប្រមូល ចងក្រង និងចែកចាយទិន្នន័យ តាមផ្នែកពាក់ព័ន្ធសំខាន់ៗ ។

ថ្ងៃ ច័ន្ទ ១៧ រោច ខែ ភទ្របទ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ២០២២

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ-ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្ដីរាយការណ៍"

-ឯកឧត្ដម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ២៤៤លើក) មនុស្សចំនួន ១.០៤៩នាក់(ស្រី ៥៤០នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | **បានសម្របសម្រួលចំនួន ១២២លើក អ្នកចូលរួមសរុបចំនួន ៥៧៧នាក់(ស្រី ៣០០នាក់)**<br>▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាអធិបតី និងចូលរួម៖<br>១-កិច្ចប្រជុំពិនិត្យ និងកែសម្រួលអនុស្សរណៈយោគយល់រវាង គ.ជ.ប.ជ និងអង្គការវីនរ៉ក់អន្តរជាតិ នៅសាលប្រជុំ គ.ជ.ប.ជ។ ២-បើកសិក្ខាសាលា ការប្រកាសគម្រោងអនុវត្តរួមគ្នា ស្តីពីទេសន្តប្រវេសន៍ដោយសុវត្ថិភាព រវាងអង្គការការីតាសស្វីស និងអង្គការតំណក់ទឹក ជាមួយ គ.ជ.ប.ជ ចំនួន ០២លើក។ ៣-កិច្ចប្រជុំរបស់គណៈកម្មការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។ ៤-ក្នុងពិធីបើកវគ្គបំប៉នសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំ ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ជូនដល់ថ្នាក់ដឹកនាំរបស់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តបន្ទាយមានជ័យ។ ៥-ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២២ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅវិមានសន្តិភាព។ ៦-ក្នុងពិធីបើកវគ្គបំប៉នសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំ ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ជូនដល់ថ្នាក់ដឹកនាំរបស់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តប៉ៃលិន។ ៧-បិទកម្មវិធី សិក្ខាសាលាកែសម្រួលសៀវភៅគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប លើកទី២ នៅសណ្ឋាគារសោន់វ៉េភ្នំពេញ។ ៨-ក្នុងពិធីបើកសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ និងបូកសរុបលទ្ធផលប្រលងប្រណាំងភូមិ-ឃុំ មានសុវត្ថិភាព របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសណ្ឋាគារសុខាភ្នំពេញ។ ៩-ក្នុងវេទិកា ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សតាមរយៈអនឡាញ ក្រោមប្រធានបទ កូវីដ-១៩ ការជួញដូរមនុស្ស និងបច្ចេកវិទ្យា ដែលរៀបចំដោយ ផ្នែកជួញដូរមនុស្សដោយ UNDOC អង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៅដីហ្វេកធូរីភ្នំពេញ។ ១០-ក្នុងកិច្ចប្រជុំពិភាក្សាស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងវិស័យនេសាទនៅអាស៊ីអាគ្នេយ៍ រៀបចំសម្របសម្រួលដោយបណ្តាញភ្នាក់ងារគាំពារលើវិស័យការងារ Labour Protection network (LPN) របស់គម្រោងអាស៊ាន-អូស្ត្រាលី ASEAN-Australia លើវិស័យប្រឆាំងការជួញដូរមនុស្ស មានអ្នកចូលរួមប្រមាណ ៥០០នាក់(ស្រី ២៧៨នាក់)។ ១១-ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ២០២២ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង ក្រោមអធិបតីភាពឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍជនបទ និងជាប្រធានក្រុមការងារចុះតាមដានត្រួតពិនិត្យគោលនយោបាយរាជរដ្ឋាភិបាល។ ១២-ក្នុងកិច្ចប្រជុំបន្តដើម្បីពិនិត្យនិង កែសម្រួលខ្លឹមសារ និងប្រមូលធាតុចូលលើឯកសារ SOP សម្រាប់កិច្ចប្រជុំទ្វេភាគី រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(កម្ពុជា) និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខ |

មនុស្ស(ថៃ) ស្តីពី «ស្តង់ដារនៃនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់» ០៣លើក មានអ្នកចូលរួម ៣១នាក់ ស្រី ១១នាក់។ **១៣**-ក្នុងកិច្ចប្រជុំពិភាក្សា
យុទ្ធសាស្ត្រ ជាមួយឯកឧត្តម **ហួ រ៉ៅ្ស** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងលោក ម៉ាក ថៃយល័រ ប្រធានគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
នៅកម្ពុជា របស់អង្គការវីនរ៉ក់អន្តរជាតិ ស្តីពីកិច្ចការពារសិទ្ធិ និងសុវត្ថិភាពពលករទេសន្តរប្រវេសន៍ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស
សិក្ខាសាលាផ្សព្វផ្សាយសមិទ្ធផល និងបិទបញ្ចប់គ្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព រវាងគ.ជ.ប.ជ និងអង្គការឃែរអន្តរជាតិ (CARE International) ដែល **១៤**-ក្នុងការបើកអង្គ
មានខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ជាខេត្តគោលដៅនៃគម្រោង មានអ្នកចូលរួមសរុប ៧៤នាក់។ **១៥-ក្នុងការ**បើក និងបិទវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ
និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាននៅខេត្តកោះកុង សហការជាមួយអាស៊ានអាក់(Asean-Act)។ **១៥**-ក្នុងកិច្ច
ប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២២ របស់រដ្ឋបាលខេត្តសៀមរាប។

- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖

១-កិច្ចប្រជុំពិនិត្យ និងកែសម្រួលអនុស្សរណៈយោគយល់រវាងគ.ជ.ប.ជ និងអង្គការវីនរ៉ក់អន្តរជាតិក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ
នៅសាលប្រជុំ គ.ជ.ប.ជ។ **២**-ការបើកកិច្ចប្រជុំពាក់ព័ន្ធការធ្វើបច្ចុប្បន្នភាព លើគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរង
គ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។ **៣**-
កិច្ចប្រជុំរបស់គណៈកម្មការសម្របសម្រួលថ្នាក់ជាតិ ប្រឆាំងការសម្អាតប្រាក់នឹងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ក្រោម
អធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ **៤**-ជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ
ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តបាត់ដំបង។ **៥**-និងទទួលស្ត្រីពពោះជំនួស ទៅសម្រាកនៅមន្ទីរពេទ្យ១៦ឧសភា។ **៦**-ក្នុងពីធីប្រកាស
គម្រោងនៅមជ្ឈមណ្ឌលទទួលពលករនៅស្រុកកំរៀង ខេត្តបាត់ដំបង។ **៧**-កិច្ចប្រជុំក្រុមការងារយេនឌ័រ របស់ក្រសួងមហាផ្ទៃ នៅក្រសួងមហាផ្ទៃ។ **៨**-ជាអធិបតី
ភាពក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន រៀបចំដោយ
អង្គការ UNICEF។ **៩**-ពិធីបើកសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ និងបូកសរុបលទ្ធផលប្រលងប្រណាំង ភូមិ-ឃុំ មាន
សុវត្ថិភាព របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅសណ្ឋាគារសុខាភ្នំពេញ។

- ចូលរួមកិច្ចប្រជុំជាមួយអង្គការចាប់ដៃ នៅសាលប្រជុំ គ.ជ.ប.ជ។ **១០**-ក្នុងកិច្ចប្រជុំពិភាក្សាស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្នុងវិស័យនេសាទនៅអាស៊ី

អាគ្នេយ៍ រៀបចំសម្របសម្រួលដោយបណ្តាញភ្នាក់ងារគាំពារលើវិស័យការងារ Labour Protection network (LPN) របស់គម្រោងអាស៊ាន-អូស្ត្រាលី ASEAN-
Australia លើវិស័យប្រឆាំងការជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ **១១**-ពិនិត្យ និងកែសម្រួលខ្លឹមសារ និងប្រមូលធាតុចូលលើឯក
សារ SOP សម្រាប់កិច្ចប្រជុំទ្វេភាគី រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខ
មនុស្ស នៃរាជរដ្ឋាភិបាលថៃ ស្តីពី «ស្តង់ដារនៃនីតិវិធី ប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់»។ **១២**-ក្នុងកិច្ចប្រជុំពិភាក្សាយុទ្ធសាស្ត្រ ស្តីពីកិច្ចការពារ
សិទ្ធិ និងសុវត្ថិភាពពលករទេសន្តរប្រវេសន៍ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយអង្គការវីនរ៉ក់អន្តរជាតិ ដែលមានលោក **ម៉ាក ថៃយល័រ** ប្រធាន

គម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។ ១៣-សិក្ខាសាលាផ្សព្វផ្សាយសមិទ្ធផល និងបិទបញ្ចប់គម្រោង ចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការថែរអន្តរជាតិប្រចាំប្រទេសកម្ពុជា (CARE International) ដែលមានខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ជាខេត្តគោលដៅនៃគម្រោង។ ១៤-កិច្ចប្រជុំពិភាក្សាស្តីពី គម្រោងអភិវឌ្ឍសមត្ថភាពភាសាបរទេស (ខ្មែរ-ថៃ) និងការចុះក្នុងតំបន់ដើម្បីសួរសុខទុក្ខការអនុវត្តន៍គម្រោងនៅតាមសាលារៀនក្នុងខេត្តកោះកុង "គាំទ្រដោយអង្គការ Cambodia Acts និងអង្គការ Plan International។ ១៥-បើកវគ្គបណ្តុះបណ្តាលស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស នៅខេត្តកោះកុង ដោយមានកិច្ចសហការជាមួយអង្គការ Asean-Act។ ១៦-ជាអធិបតីភាពកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២២ របស់រដ្ឋបាលខេត្តសៀមរាប។

- **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** ១-លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ៥១ច្បាប់ លិខិតចូល ៤៣ច្បាប់។ ២-លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ២៧ច្បាប់ លិខិតចូល ៤៨ច្បាប់។ ៣-រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។ ៤-បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមករា កុម្ភៈ មីនាឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ៥-បូកសរុបរបាយការណ៍ខែមករា កុម្ភៈ មីនា ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ៦-ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។ ៧-រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។ ៨-ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារតី។ ៩-ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។ ១០-ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ Wiki ncct Convert ជា PDF បានចំនួន ១៨៣ច្បាប់ និងបានចងក្រងជាសៀវភៅជាក់ជូនលោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ១១-គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ ១២- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ។ ១៣-ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៩៦ច្បាប់ និងបានចងក្រងជាសៀវភៅជាក់ជូន លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។ ១៤-អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន ៣៨សកម្មភាព។
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់** លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួម៖
- ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.នៅខេត្តបាត់ដំបង។

- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.នៅខេត្តកោះកុង សហការជាមួយអាស៊ានអាក់(ASEAN-ACT)។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ៖**

-ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានអញ្ជើញចូលរួម៖

**១**-ធ្វើបទបង្ហាញជូនដល់ កងវិស្វកម្មសំណង់លេខ៤៣២ ស្តីពីទម្រង់នៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ច នៅសាលាហ្វឹកហ្វឺនកងកម្លាំងរក្សាសន្តិភាពពហុសាសន៍ ខេត្តកំពង់ស្ពឺ។**២**-ទទួលជួប និងធ្វើកិច្ចសម្ភាសជាមួយលោកស្រី បណ្ឌិត Dr. Deanna Davy ស្តីពី ការរៀបចំយន្តការបញ្ជូនឆ្លងកាត់ព្រំដែន សម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនទេសន្តរប្រវេសន៍ដែលត្រូវបានគេកេងប្រវ័ញ្ចនៅប្រទេសមហាអនុតំបន់ទន្លេមេគង្គ ដែលរៀបចំដោយអ្នកជំនាញនៃកម្មវិធីអភិវឌ្ឍសហប្រជាជាតិ(UNDP) តាមប្រព័ន្ធអនឡាញ។ **៣**-កិច្ចប្រជុំក្រុមការងារការពារជនរងគ្រោះ ស្តីពីការពិនិត្យវាយតម្លៃលទ្ធផលការងារប្រចាំឆ្នាំ២០២១ បញ្ហាប្រឈម និងលើកទិសដៅការងារ ឆ្នាំ២០២២ ក្រោមអធិបតីភាពឯកឧត្តម **មុំ ប៊ុនថន** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅទីស្តីការក្រសួងស.អ.យ។ **៤**-សិក្ខាសាលាថ្នាក់តំបន់ ដោយមានការធ្វើបទបង្ហាញ និងចែករំលែកបទពិសោធន៍ ពី៤ប្រទេសរួមមាន ព្រះរាជណាចក្រកម្ពុជា ព្រះរាជណាចក្រថៃឡង់ដ៍ ឥណ្ឌូនេស៊ី និងភូមា ប្រធានបទ)ការបណ្តុះបណ្តាលថ្នាក់តំបន់ ស្តីពីសេចក្តីផ្តើម នៃទស្សនទាន ការធ្វើសមាហរណកម្ម ប្រកបដោយនិរន្តរភាព សម្រាប់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល រៀបចំ និងឧបត្ថម្ភ សម្របសម្រួលដោយ អង្គការ IOM ប្រចាំកម្ពុជា នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប។ **៥**-ធ្វើគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសណ្ឋាគារខេមរា ខេត្តបាត់ដំបង។ **៦**-កិច្ចប្រជុំពិភាក្សាយុទ្ធសាស្ត្រ ស្តីពីកិច្ចការពារសិទ្ធិ និងសុវត្ថិភាពពលករទេសន្តរប្រវេសន៍ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រៀបចំដោយអង្គការ វីនរ៉ក់អន្តរជាតិប្រចាំនៅកម្ពុជា តាមរយៈមូលនិធិរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ(USAID) នៅសណ្ឋាគារសាន់វេ ភ្នំពេញ។ **៧**-កិច្ចប្រជុំ ក្រុមការងារបច្ចេកទេស អន្តរក្រសួង OCSE ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេក្តីព្រាងរបាយការណ៍ នៃការសិក្សាស្រាវជ្រាវ ស្តីពីការបញ្ឈប់គ្រោះថ្នាក់ Disrupting Ham Study ការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ(DH-OCSE) ក្រោមអធិបតីភាព លោកជំទាវ ញ៉េប សុភាព អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅសណ្ឋាគារសាន់វេ ភ្នំពេញ។ **៨**-ធ្វើគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលាខេត្តកោះកុង។

-លោកឧត្តមសេនីយ៍ទោ សេក ស៊ីវេត ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ អមដំណើរលោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ ទៅមន្ទីរពេទ្យ១៦ឧសភា ដើម្បីធ្វើការសម្របសម្រួលស្ត្រីកេស៊ីពពោះជំនួស០២រូប ដែលភាគីវៀតណាម បានបង្ក្រាប និងនាំខ្លួនឱ្យមន្ត្រីមានសមត្ថកិច្ចកម្ពុជា។

| | |
|---|---|
| | -លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ បានចូលរួមសិក្ខាសាលា ស្តីពីការពិនិត្យពិភាក្សា និងប្រមូលធាតុចូលបញ្ចប់ លើនីតិវិធីការអនុវត្តគោលការណ៍ណែនាំ នៃដំណើរការមាតុភូមិនិវត្តន៍តាមផ្លូវអាកាស ក្រោមអធិបតីភាព ឯកឧត្តម ញឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅមន្ទីរសង្គមកិច្ចខេត្តព្រះសីហនុ មានសិក្ខាកាមចូលរួម ៤៦នាក់ ស្រី១១នាក់។<br>-និងបានចូលរួមបានចូលរួមធ្វើជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការអង្កេតសញ្ញាណការប៉ះទង្គិចផ្លូវចិត្តទៅលើអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពបើកលោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ នៅសណ្ឋាគារសោម៉ាទេវីអង្គរ ខេត្តសៀមរាប។<br>▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌៖** ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក ក្រុមជំនួយកិច្ចការយុត្តិធម៌ បានចូលរួម៖<br>១-បានចូលរួមប្រជុំពិនិត្យកែសម្រួលលើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ របស់គ.ជ.ប.ជ ដាក់បញ្ចូលទៅក្នុងរបាយការណ៍ឆ្នាំ២០២១ របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ និងលោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ។ **២**-បើកកិច្ចប្រជុំផ្ទៃក្នុងក្រុមជំនួយកិច្ចការយុត្តិធម៌ ដើម្បីពង្រឹងវិន័យផ្ទៃក្នុងឡើងវិញ ដឹកនាំស ម្របសម្រួលដោយ ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក។ **៣**-សិក្ខាសាលាបិទបញ្ចប់គម្រោងសិទ្ធិការងារ ស្តីពី «ការលើកកម្ពស់ និងការការពារសិទ្ធិពលករកម្ពុជាដែលមានជំនាញទាបទៅប្រទេសថៃ» នៅសណ្ឋាគារសាន់វេ ភ្នំពេញ។ **៤**-ធ្វើជាគ្រូបង្គោល ចុះទៅបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីជួរមុខក្នុងស្រុកចំនួន ១២ មកពីលេខាធិការដ្ឋាន គ.ខ.ប.ជ ចំនួន០៥ ខេត្ត (ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តពោធិ៍សាត់ ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន នៅសាលប្រជុំផ្ទៃកបណ្តុះបណ្តាលបន្តនៃមន្ទីរសុខាភិបាលខេត្តបាត់ដំបង សហការរៀបចំដោយក្រសួងសុខាភិបាល និងអង្គការមូលនីធិអប់រំកុមារ អង្គការសហប្រជាតិ UNICEF។ **៥**-ប្រជុំពិនិត្យ និងកែសម្រួលខ្លឹមសាររបាយការណ៍ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបញ្ចប់ ក្រោមការដឹកនាំសម្របសម្រួលដោយលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត អគ្គលេខាធិការ គ.ជ.ប.ជ។ **៦**-ប្រជុំជាមួយក្រុមការងារ SOMTC ក្រសួងមហាផ្ទៃ ស្តីពីកិច្ចសហការ រវាងអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ជាមួយកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្សនៅកម្ពុជា(ASEAN-ACT) ជំនួសលោកជំទាវឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា ជាជនបង្គោល និងជាប្រធានក្រុមការងារ SOMTC របស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ នៅក្រសួងមហាផ្ទៃ។ **៧**-ធ្វើជាគ្រូបង្គោល វគ្គបណ្តុះបណ្តាលស្តីពី កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន (Training on Child Protection and Identification of Human Trafficking and Abuse) នៅខេត្តកោះកុង ។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់** ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម៖<br>១-ពិធីផ្សព្វផ្សាយខ្លឹមសារអនុក្រឹត្យ និងសេចក្តីសម្រេច ស្តីពីគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទាន ភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយកាយអាវុធមហាប្រល័យ (ហ.ស.គ) នៅសណ្ឋាគារសុខាភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានហ.ស.គ។** ២-កិច្ចប្រជុំពិភាក្សាជាមួយតំណាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្រោមអធិបតីភាពលោកជំទាវ |

| | |
|---|---|
| | អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។ ៣-កិច្ចប្រជុំលើកទី១ នៃអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារត្រួតពិនិត្យរួម នៃក្រុមប្រទេស អាស៊ីប៉ាស៊ីហ្វិក អំពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្រោមអធិបតីភាពឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជាប្រធាន អ ជ.អ.នៅសណ្ឋាគារសុខាភ្នំពេញ។ ៤-សិក្ខាសាលា ស្តីពីការបង្កើតប្រព័ន្ធទំនាក់ទំនង សម្រាប់មន្ត្រីបង្គោលតំណាងថ្នាក់ជាតិ ACTIP តាមប្រព័ន្ធអនឡាញ ដែលមានរយៈពេលពីរថ្ងៃ។ ៥-កិច្ចប្រជុំ លើកទី២ នៃអនុគណៈកម្មការចំពោះកិច្ចអនុវត្តផែនការសកម្មភាពការងាររបស់ក្រុមការងារ ក្រោមអធិបតីភាព ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងជា ប្រធាន អ.អ.ជ នៅសណ្ឋាគាររ៉េស៊ីដង់សុខា ភ្នំពេញ។ ៦-កិច្ចប្រជុំរបស់ក្រុមការងារទី៣ ទទួលបន្ទុកអនុវត្តសកម្មភាពនៅក្នុងលទ្ធផលជាក់ស្តែងទី៧ និងទី៨ ក្រោម អធិបតីភាព ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ប្រធាន អ.អ.ជ និងជាសហប្រធានក្រុមការងារទី៣ ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត **នេត សាវឿន** អគ្គ ស្នងការនគរបាលជាតិ អនុប្រធានអ.អ.ជ និងជាសហប្រធានក្រុមការងារទី៣ កិច្ចប្រជុំនេះធ្វើឡើងតាមប្រព័ន្ធវីដេអូហ្សូម។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ៖**<br>- លោកជំទាវអគ្គលេខាធិការរង ទទួលបន្ទុក គ.ជ.ប.ជ បានអញ្ជើញចូលរួម៖ ១-បើកសិក្ខាសាលាស្តីពី ការប្រកាសគម្រោងអនុវត្តរួមគ្នា អំពីទេសន្តរប្រវេសន៍ដោយសុវត្ថិ ភាព រវាងអង្គការកោរីតាសស្វីស និងអង្គការតំណក់ទឹក ជាមួយគ.ជ.ប.ជ ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ ២-បើកកិច្ចប្រជុំពិនិត្យពិភាក្សា សៀវភៅគោលការណ៍ណែនាំស្តីពីបែបបទនិងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប តាមប្រព័ន្ធ ZOOM ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ ៤-និងសហការរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរង គ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន កិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយក្រសួងសុខាភិបាល ដោយមានជំនួយឧបត្ថម្ភពី សហភាពអឺរ៉ុប នៅសាលប្រជុំផ្នែកបណ្តុះបណ្តាលបន្ទុមន្ទីរសុខាភិបាល ខេត្តបាត់ដំបង។ ៥-ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប សិក្ខាសាលានេះធ្វើឡើងក្រោមកិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងប្រធានគម្រោងប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជានៃអង្គការវិនរ៉ុក នៅសាលាខេត្តបាត់ដំបង។ ៦-ប្រជុំផ្នែកបណ្តុះបណ្តាលបន្ទមន្ទីរសុខាភិបាល ខេត្តបាត់ដំបង បានបន្តធ្វើវគ្គ បណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភ។ ៧-ក្នុងកិច្ចប្រជុំពិភាក្សា ស្តីពីការប្រយុទ្ធ ប្រឆាំងអំពើជួញដូរមនុស្សក្នុងវិស័យនេសាទ នៅអាស៊ីអាគ្នេយ៍ រៀបចំសម្របសម្រួលដោយបណ្តាញភ្នាក់ងារគាំពារលើវិស័យការងារ Labour protection network (LPN) របស់គម្រោងអាស៊ាន-អូស្ត្រាលី ប្រឆាំងការជួញដូរមនុស្ស(ASEAN-ACT)។ ៨-ក្នុងកិច្ចប្រជុំគណៈកម្មាធិការចម្រុះលើកទី១១ រវាងកម្ពុជា និងសហភាពអឺរ៉ុប(EU) ដែលបានរៀបចំឡើងនៅរាជធានីភ្នំពេញ ក្នុងទម្រង់ដោយផ្ទាល់ផង និងតាមរយៈវីដេអូពីចម្ងាយផង ដឹកនាំដោយឯកឧត្តម លុយ ដាវីត រដ្ឋលេខាធិការនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងលោកស្រី PAOLA PAMPALONI អនុប្រធានគ្រប់គ្រងប្រចាំ តំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃមន្ទីរកិច្ចការបរទេសសហភាពអឺរ៉ុប។ ៩-និងដឹកនាំលោកស្រី វរសេនីយ៍ទោ **ជោង សុវត្ថី** អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិ ការអន្តរជាតិ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សាយុទ្ធសាស្ត្រ ស្តីពីកិច្ចការពារសិទ្ធិ និងសុវត្ថិភាពពលករទេសន្តរប្រវេសន៍ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស ជាមួយអង្គការវីនរ៉ក់អន្តរជាតិ លោក ម៉ាក ថៃយល័រ ប្រធានគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា។ ១០-ជំនួបពិភាក្សាការងារ រវាង SOMTC កម្ពុជាជាមួយប្រតិភូ ASEAN-ACT តាមប្រព័ន្ធវីដេអូសន្និសីទ នៅទីស្តីការក្រសួងមហាផ្ទៃ។ |

| | |
|---|---|
| | - លោកឧត្តមសេនីយ៍ត្រី **អ៊ិន មាន** ប្រធានក្រុម បានចូលរួមប្រជុំចែករំលែកព័ត៌មានបច្ចុប្បន្នភាពរបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ហ៊ូ សាមិត្ត** រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងជាប្រធានក្រុមការងារខេមរិតកម្ពុជា នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ភ្នំពេញ។<br>- លោកស្រីវរសេនីយ៍ទោ **ថោង សុវត្ថិ** អនុប្រធានក្រុម បានចូលរួមសម្របសម្រួល និងធ្វើជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកោះកុង។<br>- និងចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២២ ក្រោមអធិបតីភាព លោកជំទាវជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅខេត្តសៀមរាប<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍** ឯកឧត្តម អគ្គលេខាធិការរងទទួលបន្ទុក បានអញ្ជើញចូលរួម៖<br>- ក្នុងការរៀបចំផែនការបណ្តុះបណ្តាល ស្តីពីបែបបទនិងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប សម្រាប់បើកវគ្គបណ្តុះបណ្តាល នៅខេត្តកោះកុង។<br>- បូកសរុបទិន្នន័យពលករកម្ពុជា ដែលវិលត្រឡប់មកពីបម្រើការងារ នៅក្រៅប្រទេស ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ប្រចាំថ្ងៃទូទាំងរាជធានី ខេត្តទាំង២៥ ប្រចាំខែមករា ឆ្នាំ២០២២ បានចំនួន ៦.៨៩១នាក់(ស្រី ៣.៣២៨នាក់)។<br>- ចូលរួមសិក្ខាសាលាផ្សព្វផ្សាយសមិទ្ធផល និងបិទបញ្ចប់គ្រោង ចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព ជាមួយអង្គការយែរប្រចាំកម្ពុជា នៅសាលប្រជុំសាលាខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។<br>- ចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តកោះកុង។<br>- ចូលរួមកិច្ចប្រជុំក្រុមការងាររបាយការណ៍ ដើម្បីរៀបចំផែនការសកម្មភាពសម្រាប់កម្មវិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ២០២២ របស់គ.ជ.ប.ជ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ០៧ ខែមេសា ក្រោមការដឹកនាំសម្របសម្រួលដោយឯកឧត្តម **ខៀវ ចាន់រ៉ា** អគ្គលេខាធិការរង គ.ជ.ប.ជ។ |
| **ក្រុមការងារទាំង ៦របស់អន្តរក្រសួង បានសម្របសម្រួលចំនួន ៥២លើក អ្នកចូលរួមសរុបចំនួន ៨២នាក់(ស្រី ២៥នាក់)** | |
| ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ▪ **ក្រុមការងាររបស់ក្រសួងបានចូលរួម៖** ១-សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការរៀបចំផែនការជាតិសម្រាប់ការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (GCM) ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២ នៅសណ្ឋាគារកាំបូឌីយ៉ាណា។ ២-កិច្ចប្រជុំអន្តរក្រសួងដើម្បីពិនិត្យ និងពិភាក្សាលើទម្រង់នៃការឡើងការពាររបាយការណ៍ជាតិរបស់កម្ពុជា ស្តីពីការអនុវត្តកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនាថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ តាមប្រព័ន្ធ Zoom។ ៣-កិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងថៃ លើកទី១១ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២១ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ៤-ក្នុងកិច្ចប្រជុំពិភាក្សាស្តីពីការតភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តិកម្ម Online ដើម្បីបន្តសុពលភាពបណ្ណពលករកម្ពុជា (OCWC) និងលិខិតធ្វើដំណើរពលករកម្ពុជាធ្វើនៅបរទេស (TD) ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ១១ ខែមករា ឆ្នាំ២០២២។ ៥-កិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគី ដើម្បីលើកកម្ពស់ការប្រើប្រាស់ពលករទេសន្តរប្រវេសន៍ដោយត្រឹមត្រូវ និងប្រកបដោយក្រមសីលធម៌រវាងកម្ពុជា-ថៃ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២ នៅសណ្ឋាគារសូហ្វីតែល អង្គរភូគីត្រា នៅខេត្តសៀមរាប។ ៦-កិច្ចប្រជុំ ដើម្បីពិនិត្យ |

| | |
|---|---|
| | ប្រមូលធាតុចូលលើឯកសារ SOP សម្រាប់កិច្ចប្រជុំទ្វេភាគីរវាងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៃរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្សនៃរាជរដ្ឋាភិបាលថៃ ស្តីពីស្តង់ដានៃនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៤ មីនា ឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ។ ៧-កិច្ចប្រជុំត្រួតពិនិត្យ និងឆ្លើយតបកម្រងសំណួរពាក់ព័ន្ធនឹងពលកម្មកុមារនៅប្រទេសកម្ពុជារបស់ក្រសួងការងារនៃសហរដ្ឋអាមេរិកចំនួន ១លើក។ ៨-សហការជាមួយអង្គការ IOM ក្នុងការរៀបចំយុទ្ធនាការណ៍ផ្សព្វផ្សាយពីសេវាការងារក្នុងស្រុក និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅក្នុងខេត្តបន្ទាយមានជ័យ នាថ្ងៃទី៨ ដល់ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២។ ៩-វគ្គបណ្តុះបណ្តាលថ្នាក់តំបន់ លើវិធីសាស្រ្តរួមបញ្ចូលគ្នាក្នុងការធ្វើសមាហរណកម្មពលករទេសន្តប្រវេសន៍ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី៧-៩ ខែកុម្ភៈ ឆ្នាំ២០២២ នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប។ ១០-សិក្ខាសាលាបិទបញ្ចប់គម្រោងសិទ្ធិការងារ "ការលើកកម្ពស់ និងការការពារសិទ្ធិពលករកម្ពុជាដែលមានជំនាញទាបទៅធ្វើការនៅប្រទេសថៃ" ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៨-១៩ ខែមករា ឆ្នាំ២០២២ នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។ ១១-ពិនិត្យផ្តល់ធាតុចូល និងមតិយោបល់លើរបាយការណ៍សិក្សា ស្តីពីពលករទេសន្តប្រវេសន៍ជាស្ត្រីនៅក្នុងច្បាប់និងគោលនយោបាយនៃរដ្ឋសមាជិកអាស៊ាន និងចូលរួមសិក្ខាសាលាផ្ទៀងផ្ទាត់របាយការណ៍សិក្សាខាងលើ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ។ ១២-កិច្ចប្រជុំបណ្តាញសមាជិក នៃគម្រោងកម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ ដែលបានព្រឹត្តទៅនាថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ តាមប្រព័ន្ធ Zoom។ ១៣-ក្នុងកិច្ចប្រជុំក្រុមការងារការពារជនរងគ្រោះ ស្តីពី "ការពិនិត្យ វាយតម្លៃលទ្ធផលការងារប្រចាំឆ្នាំ២០២១ បញ្ហាប្រឈម និងលើកទិសដៅការងារឆ្នាំ២០២២" ដែលបានប្រព្រឹត្តទៅនាថ្ងៃទី២១ ខែមករា ឆ្នាំ២០២២។ ១៤-កិច្ចប្រជុំពិនិត្យពិភាក្សា និងធ្វើបច្ចុប្បន្នភាពសៀវភៅគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលបានប្រព្រឹត្តទៅនាថ្ងៃទី២៥ ខែមករា ឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ។ ១៥-សិក្ខាសាលាផ្ទៀងផ្ទាត់ថ្នាក់ជាតិ បង្ហាញគំហើញសំខាន់ៗ នៃការវាយតម្លៃកម្មវិធីអាស៊ាន-ACT ដែលបានប្រព្រឹត្តទៅនាថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ។ ១៦-សិក្ខាសាលាផ្សព្វផ្សាយសមិទ្ធផលនិងបិទបញ្ចប់គម្រោងចំណាកស្រុកឆ្លងដែនដោយសុវត្ថិភាព ដែលបានប្រព្រឹត្តទៅនាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ នៅសាលប្រជុំសាលាខេត្តកំពង់ស្ពឺ។ ១៧-សិក្ខាសាលាស្តីពីការពិនិត្យ ពិភាក្សានិងប្រមូលធាតុចូលបញ្ចប់លើនីតិវិធីការអនុវត្តគោលការណ៍ណែនាំ នៃដំណើរការមាតុភូមិនិវត្តន៍ជនរងគ្រោះដោយសារអំពើជួញដូរមនុស្ស ដែលបានប្រព្រឹត្តទៅនាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២ នៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ខេត្តព្រះសីហនុ។ ១៨-ធ្វើបទបង្ហាញនៅក្នុងកិច្ចប្រជុំកំពូល G20 លើកទី១ ក្រោមមូលបទ "ការធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារដើម្បីស្តារឡើងវិញរួមគ្នា" ដែលបានប្រព្រឹត្តទៅពីថ្ងៃទី៨ ដល់ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ។ ១៩-កិច្ចប្រជុំក្រុមការងារបច្ចេកទេសលើកកម្ពស់ការយល់ដឹង និងទប់ស្កាត់អំពើហិង្សាលើកុមារ ក្នុងគោលបំណងពិនិត្យ និងកែសម្រួលឯកសារបណ្តុះបណ្តាលសម្រាប់ផ្សព្វផ្សាយនៅតាមសហគមន៍របស់យុទ្ធនាការគ្រួសាររឹងមាំពាក់ព័ន្ធពលកម្មកុមារចំនួន ៣លើក (ខេត្តកែប ខេត្តកំពត និងខេត្តសៀមរាប)។ ២០-កិច្ចប្រជុំពិភាក្សាអំពីសេវាថែទាំកុមារនៅក្នុងរោងចក្រ សហគ្រាសធំៗ ក្នុងកម្មវិធីរបស់សារព័ត៌មាន Khmer Times នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២២។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | -បានសហការជាមួយក្រសួងសុខាភិបាល និងមន្ទីរពេទ្យកាល់ម៉ែត សម្របសម្រួលជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ទទួលការពិនិត្យនិងព្យាបាលជំងឺ ០១នាក់ (វះកាត់បេះដូង)។ |

| | |
|---|---|
| | -លោកស្រី **ព្រំ សុខន** ប្រធាននាយកដ្ឋាន និងលោកស្រី **ឈា ម៉ានិត** ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានជួបសម្ភាសជាមួយទីប្រឹក្សាអង្គការ UNDP តាមប្រព័ន្ធអនឡាញ ស្តីពី Development of a transnational referral mechanism for trafficked persons and exploited migrants in the Greater Mekong Sub region.<br>-បានចូលរួមកិច្ចប្រជុំ ដែលរៀបចំដោយក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចំនួន ០៤លើក។<br>-បានសហការជាមួយ ក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការសង់ត្រាល់ ដើម្បីធ្វើការសម្របសម្រួលបញ្ជូនស្ត្រីពរពោះជំនួសចំនួន ០២នាក់ ឱ្យបានទទួលការស្នាក់នៅ ការពិនិត្យតាមដាន និងការថែទាំបណ្តោះអាសន្ននៅមន្ទីរពេទ្យ ១៦ឧសភា។<br>-បានចុះវាយតម្លៃលើមន្ត្រី ស.អ.យ ក្រុង/ស្រុក ដែលធ្លាប់បានទទួលការបណ្តុះបណ្តាលលើគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការនំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប បានចំនួន ០៥លើក នៅក្នុងខេត្តចំនួន ០៥ មានខេត្ត(ក្រចេះ កំពង់ចាម កំពង់ធំ ព្រៃវែង និងខេត្តស្វាយរៀង) មានអ្នកចូលរួមសរុបចំនួន ៧៩នាក់(ស្រី ២៥នាក់) ដោយមានការគាំទ្រពីអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM)។<br>-ក្រុមការងារការិយាល័យសមាហរណកម្ម និងកិច្ចការពារជនរងគ្រោះបានសហការជាមួយមន្ត្រីថ្នាក់ខេត្ត/ស្រុក និងអង្គការដៃគូ ក្នុងការស្វែងរកគ្រួសារ ដើម្បីចុះធ្វើការកំណត់អត្តសញ្ញាណ និងសមាហរណកម្មជនរងគ្រោះទៅសហគមន៍វិញ ដែលមានទីតាំងស្ថិតនៅរាជធានី-ខេត្ត ចំនួន ១៥ ដូចជា៖ រាជធានីភ្នំពេញ ខេត្ត(ព្រះសីហនុ កំពត កណ្តាល ព្រៃវែង ស្វាយរៀង កំពង់ចាម ត្បូងឃ្មុំ ក្រចេះ រតនៈគិរី ស្ទឹងត្រែង កំពង់ធំ សៀមរាប ព្រះវិហារ និងខេត្តបាត់ដំបង)។<br>-បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការរំលោភពាន នៅខេត្តកោះកុង ០១លើក។<br>- លោកស្រី **ឈា ម៉ានិត** ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានចូលរួម៖ ១-សិក្ខាសាលា ស្តីពី ការធ្វើបច្ចុប្បន្នភាពលើសារាចរណែនាំការងារសមាហរណកម្ម តាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងសហគមន៍ និងទម្រង់គ្រប់គ្រងករណី ០១លើក។ ២-ប្រជុំពិនិត្យពិភាក្សាបន្ត និងធ្វើបច្ចុប្បន្នភាពសៀវភៅគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់ អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។<br>-ចូលរួមកិច្ចប្រជុំរបស់ក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ០២លើក៖១.កិច្ចប្រជុំក្រុមការងារខេមមីត និងក្រុមជំនួយកិច្ចការសហប្រតិបត្តិកាតអន្តរជាតិ។ ២.កិច្ចប្រជុំត្រៀមប្រជុំទ្វេភាគី កម្ពុជា-ថៃ ស្តីពីស្តង់ដារនីតិវិធីប្រតិបត្តិសម្រាប់កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៧០លើក អ្នកចូលរួមសរុបចំនួន ៣៩០នាក់(ស្រី ២១៥នាក់)** | |
| ខេត្តកណ្តាល | -លោកជំទាវ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ និងក្រុមការងារខេត្ត បានចូលរួម៖<br>○ បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ លើសេចក្តីព្រាងបទដ្ឋាននីតិវិធីប្រតិបត្តិការ ស្តីពីកិច្ចការពារកុមារ នៅខេត្តកំពង់ធំ ក្រោមអធិបតីភាពឯកឧត្តម **ប្រាក់ សំអឿន** អគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ។<br>○ ពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នូវសៀវភៅរបាយការណ៍ របស់គណៈកម្មាធិការអាស៊ាន ស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ស្តីពីអត្តសញ្ញាណស្របច្បាប់សម្រាប់ស្ត្រី និងកុមារក្នុងតំបន់អាស៊ាន តាមប្រព័ន្ធ Zoom ក្រោមអធិបតីភាពឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ |

| | |
|---|---|
| | ○ ក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារនៃព្រះរាជាណាចក្រកម្ពុជា។<br>○ ប្រជុំ ស្តីពីការត្រួតពិនិត្យការងារប្រឆាំងការសម្អាតប្រាក់ និងពង្រឹងកិច្ចសហការស៊ើបអង្កេតស្រាវជ្រាវផលនៃបទល្មើសសម្អាតប្រាក់ ដែលបានមកពីបទល្មើសជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងទម្រង់ផ្សេងទៀតតាមប្រព័ន្ធ Zoom។<br>○ ក្នុងវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ ការកេងប្រវ័ញ្ចផ្លូវភេទកុមារ នៅសណ្ឋាគារភ្នំពេញ។<br>-មន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តចំនួន០៥នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់សញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស តាមប្រព័ន្ធ Zoom អ្នកចូលរួមចំនួន១៤០នាក់ ស្រី៥៥នាក់។ |
| ខេត្តព្រៃវែង | -លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមជាអធិបតីភាពបើកវគ្គណែនាំ ស្តីពីការអនុវត្តគម្រោងកិច្ចការពារកុមារ និង ការគ្រប់គ្រងថវិកាជូនដល់ក្រុមការងារកិច្ចការពារកុមារ និងមន្ត្រីពិនិត្យបញ្ជាក់នៃគម្រោងលើកកម្ពស់សេវាសង្គម ដែលទទួលការគាំទ្ររបស់យូនីសេហ្វដល់ក្រុមការងារកិច្ចការពារកុមារ និងមន្ត្រីទទួលបន្ទុកខេត្តព្រៃវែង ក្រចេះ និងខេត្តរតនគិរី រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងមហាផ្ទៃ និងគាំទ្រដោយអង្គការយូនីសេហ្វ។<br>-មន្ត្រីជំនាញនៃមន្ទីរកិច្ចការនារី បានចូលរួមវគ្គបណ្តុះបណ្តាល ០២លើក៖ ១.ស្តីពីការទប់ស្កាត់ការរំលោភបំពានលើស្ត្រី និងកុមារ រៀបចំដោយក្រសួងកិច្ចការនារី នៅខេត្តស្ទឹងត្រែង។ ២.ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចនានា និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន នៅខេត្តតាកែវ។ |
| ខេត្តសៀមរាប | -ក្រុមការងារលេខាធិការដ្ឋាន ក្រុមការងារកិច្ចការអនុវត្តច្បាប់ និងក្រុមការងារកិច្ចការទេសន្តរប្រវេសន៍ បានចូលរួមសិក្ខាសាលាបិទបញ្ចប់គម្រោងសិទ្ធិការងារ ស្តីពីការលើកកម្ពស់ការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ។<br>-មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ស្នងការដ្ឋាននគរបាលខេត្ត និងកងរាជអាវុធហត្ថខេត្ត បានធ្វើការប្រជុំពិភាក្សាលើកការកំណត់នីតិវិធីក្នុងការទប់ស្កាត់ និងដកហូតកុមារក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ នៅតាមសហគ្រាសអាជីវកម្មផលិតឥដ្ឋ ចំនួន០១លើក អ្នកចូលរួមចំនួន ០៨នាក់(ស្រី ០៤នាក់)។<br>-ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំប្រចាំខែកុម្ភៈ ឆ្នាំ២០២២ ចំនួន០៥លើក អ្នកចូលរួមចំនួន ១៦១នាក់ ស្រី ៥៥នាក់៖<br>○ ក្រុមការងារស្រុកសូទ្រនិគម ចំនួន០១លើក អ្នកចូលរួមចំនួន៣២នាក់ ស្រី០៩នាក់។<br>○ ក្រុមការងារស្រុកពួក ចំនួន ០១លើក អ្នកចូលរួមចំនួន៤៤នាក់ ស្រី១៦នាក់។<br>○ ក្រុមការងារស្រុកស្វាយលើ ចំនួន ០១លើក អ្នកចូលរួមចំនួន២២នាក់ ស្រី០៨នាក់។<br>○ ក្រុមការងារស្រុកអង្គរជុំ ចំនួន០២លើក អ្នកចូលរួមចំនួន៦៣នាក់ ស្រី២២នាក់។<br>-លេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធចំនួន០៥លើក៖<br>○ លោកជំទាវប្រធានលេខាធិការដ្ឋាន បានចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំងលទ្ធផលការងារនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២២ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ចំនួន០១លើក នៅរដ្ឋបាលសាលាខេត្ត។ |

| | |
|---|---|
| | ○ លោកជំទាវប្រធានលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្តលើទី៣២ អាណត្តិទី៣ ចំនួន ០១លើក តាមប្រព័ន្ធ Zoom។<br>○ ឯកឧត្តមអភិបាល នៃគណៈភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ និងលោកជំទាវប្រធានលេខាធិការដ្ឋាន បានអញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២-២០២១ និងលើកផែនការការងារឆ្នាំ២០២២ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំនួន០១លើក តាមប្រព័ន្ធ Zoom។<br>○ លោកជំទាវប្រធានលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំជាមួយអង្គការ UNICEF ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២២ របស់ក្រុមការងារកិច្ចការពារកុមារ ចំនួន០១លើក តាមប្រព័ន្ធ Zoom។<br>-លោកជំទាវប្រធានលេខាធិការដ្ឋាន បានចូលរួមពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នូវសៀវភៅរបាយការណ៍របស់គណៈកម្មាធិការអាស៊ាន ស្តីពីការលើកកម្ពស់និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ស្តីពីអត្តសញ្ញាណស្របច្បាប់សម្រាប់ស្ត្រីនិងកុមារ ក្នុងតំបន់អាស៊ាន តាមប្រព័ន្ធ Zoom។<br>-លោកស្រីប្រធាន អនុប្រធាន លេខាធិការដ្ឋាន បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការយល់ដឹងពីមូលដ្ឋាននៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកិច្ចការពារកុមារដល់បុគ្គលិកសង្គម និងមន្ត្រីជួរមុខនៅសហគមន៍ ០១លើក។<br>-លេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើការសម្របសម្រួលជូន អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងអង្គការ IOM លើការចាត់អញ្ជើញសិក្ខាកាមចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការអង្កេតសញ្ញាណនៃការប៉ះទង្គិចផ្លូវចិត្តទៅលើជនរងគ្រោះដោយអំពើជួញដូរមនុស្ស ០១លើក។ |
| **ខេត្តបាត់ដំបង** | - បានចូលរួមប្រជុំត្រីមាសទី១ របស់គម្រោងស្តីពី សុវត្ថិភាពទេសន្តរប្រវេសន៍នៅកម្ពុជា រយៈ០៣ឆ្នាំ(២០២២-២០២៤) គាំទ្រដោយអង្គការការីតាស់ស្វីស។<br>- បានចូលរួមជាគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងសិទ្ធិទទួលបានការងារ ០១លើក អ្នកចូលរួម ១៦នាក់ ស្រី១៣នាក់។<br>- បានចូលរួមសិក្ខាសាលាស្តីពី ការធ្វើបច្ចុប្បន្នភាពលើកសារាចរណ៍ណែនាំការងារសមាហរណកម្មតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលនិងសហគមន៍ និងទម្រង់គ្រប់គ្រងករណីជនរងគ្រោះដោយអំពើជួញដូរមនុស្ស ០១លើក នៅនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។ |
| **ខេត្តបន្ទាយមានជ័យ** | - ឯកឧត្តម អភិបាលនៃគណអភិបាលខេត្ត និងជាប្រធានគ.ខ.ប.ជខេត្ត បានដឹកនាំកិច្ចប្រជុំបូកសរុបរបាយការណ៍ប្រចាំឆ្នាំ២០២១ និងលើកទិសដៅឆ្នាំ២០២២ និងប្រកាសសមាសភាពគណកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត។<br>- លោកស្រី និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ លើសេចក្តីព្រាងបទដ្ឋាននីតិតវិធីប្រតិបត្តិការ ស្តីពីកិច្ចការពារកុមារ។<br>- ស្នងការនគរបាលខេត្ត<br>○ បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ស្តីពី សេចក្តីណែនាំអំពីការស៊ើបអង្កេតអំពើកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅខេត្តសៀមរាប។ |

| | |
|---|---|
| | ○ បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញ ស្តីពី ការស៊ើបអង្កេត និងការឆ្លើយតបចំពោះបទល្មើសផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធើណែត នៅខេត្តបាត់ដំបង។<br>○ បានចូលរួមប្រជុំស្តីពី ការត្រួតពិនិត្យការងារប្រឆាំងការសម្អាតប្រាក់ និងពង្រឹងកិច្ចសហការស៊ើបអង្កេតផលនៃបទល្មើសសម្អាតប្រាក់ ដែលបានមកពីបទល្មើសជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងទម្រង់ផ្សេងៗទៀតនាំបទល្មើសជួញដូរមនុស្ស តាមប្រព័ន្ធ ZOOM។<br>- ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ លើសេចក្តីព្រាងបទដ្ឋាននីតិវិធីប្រតិបត្តិការ ស្តីពីកិច្ចការពារកុមារ។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំត្រៀមបើកវគ្គបណ្តុះបណ្តាល ស្តីពី«កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន» តាមប្រព័ន្ធ Zoom។<br>- ប្រធានលេខាធិការដ្ឋាន និងក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមរៀនវគ្គបណ្តុះបណ្តាល ស្តីពី«កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន» នៅសាលាខេត្តបាត់ដំបង។<br>- ស្នងការដ្ឋាននគរបាលខេត្ត<br>○ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធ Zoom នៅរាជធានីភ្នំពេញ។<br>○ បានចូលរួមវគ្គបណ្តុះបណ្តាលលើកទី២ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងនីតិវិធីស៊ើមអង្កេត តាមប្រព័ន្ធ Zoom។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងរំលោភបំពាន ធ្វើនៅមន្ទីរសុខាភិបាលខេត្តបាត់ដំបង។<br>- លោកស្រី **ឈា ម៉ានិត** ប្រធានមណ្ឌលសំចតប៉ោយប៉ែតបានចូលរួម៖<br>○ សិក្ខាសាលា ស្តីពីការធ្វើបច្ចុប្បន្នភាពលើ សារាចរណ៍ណែនាំការងារសមាហរណកម្មតាមដានជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលស្នាក់នៅក្នុងមណ្ឌល និងសហគមន៍ និងទម្រង់គ្រប់គ្រងករណី ០១លើក។<br>○ ប្រជុំពិភាក្សាបន្ត និងធ្វើបច្ចុប្បន្នភាព សៀវភៅគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ០១លើក។ |
| ខេត្តតាកែវ | - មន្ទីរកិច្ចការនារីខេត្ត<br>○ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការរំលោភបំពានផ្លូវភេទលើស្ត្រី នៅខេត្តសៀមរាម។<br>○ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការវិភាគលើការអនុវត្តគោលនយោបាយ ឆ្លើយតបនឹងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ នៅខេត្តកោះកុង។ |

| | |
|---|---|
| | ○ បានចូលរួមសិក្ខាសាលា ស្តីពីសិទ្ធិកុមារនិងច្បាប់កិច្ចការពារកុមារនានាដែលពាក់ព័ន្ធទៅនឹងកិច្ចការពារ និងផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធការពារកុមារ នៅខេត្តតាកែវ។ |
| **ខេត្តកែប** | - លោកជំទាវ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំលេខាធិការដ្ឋាន គ.ខ.ប.ជ ចំនួន០១លើក ដើម្បីណែនាំដល់មន្ទីរ អង្គភាពពាក់ព័ន្ធរៀបចំផែនការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ |
| **ខេត្តក្រចេះ** | - ស្នងការដ្ឋាននគរបាលខេត្ត បានចាត់មន្ត្រីនគរបាលចំនួន០៦រូប ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស រៀបចំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ។<br>- ស្នងការដ្ឋាននគរបាលខេត្តបានចាត់មន្ត្រីនគរបាលចំនួន០៦រូប ស្រី០១រូប ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស ដែលរៀបចំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ ០១លើក។ |
| **ខេត្តកំពង់ចាម** | - លេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមកិច្ចសិក្ខាសាលាបិទបញ្ចប់វគ្គគម្រោងសិទ្ធិការងារ ការលើកកម្ពស់ និងការការពារសិទ្ធិពលករកម្ពុជា ដែលមានជំនាញទាបទៅប្រទេសថៃ នៅរាជធានីភ្នំពេញ។<br>- លោកស្រី **ង៉ោក ចរិយា** អនុប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី"ការគ្រប់គ្រង និងការបញ្ជូនករណីជនរងគ្រោះដោយអំពើជួញដូរមនុស្ស" ដែលរៀបចំដោយអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រីនឹងកុមារ នៅសណ្ឋាគារភ្នំប្រុស ០១លើក។<br>- ក្រុមការងារទេសន្តរប្រវេសន៍របស់មន្ទីរការងារបានចូលរួមប្រជុំតាមZoom ជាមួយអង្គការ ILO ១លើក ដើម្បីពិភាក្សាការងារអាទិភាពសម្រាប់ឆ្នាំ២០២២ ។<br>- លោកស្រី **ខៀវ សុជាតិ** សមាជិកក្រុមការងារទេសន្តរប្រវេសន៍ ប្រជុំជាមួយក្រុមការងារ និងលេខាធិការដ្ឋាន គ.ខ.ប.ជ នៅសាលាខេត្ត០២លើក ព្រមទាំងបានធ្វើបទបង្ហាញអំពី នីតិវិធីទៅធ្វើការស្របច្បាប់នៅក្រៅប្រទេសចំនួន ០១លើក នៅស្រុកស្ទឹងត្រង់ អ្នកចូលរួម២២នាក់ស្រី០៩នាក់។ |
| **ខេត្តឧត្តរមានជ័យ** | - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន។ |
| **ខេត្តប៉ៃលិន** | - លោកជំទាវ **បាន ស្រីមុំ** អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការកិត្តិយសសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព លោកស្រី **ឡូញ ឈាង** អភិបាលរងខេត្ត និងជាអនុប្រធានគណៈកម្មាធិការកិត្តិយសសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព បានចូលរួមវគ្គប៉ំប៉នពង្រឹងសមត្ថភាពស្ត្រីថ្នាក់ដឹកនាំ ក្រុង-ស្រុក ឃុំ-សង្កាត់ នៃខេត្តប៉ៃលិនក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** សមាជិកគណៈកម្មាធិការកណ្តាល អនុប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍ ។<br>- លោកស្រី **ឡូញ ឈាង** អភិបាលរងខេត្ត និងលោក **ស្រេង វិច្ឆិកា** នាយករងទីចាត់ការអន្តរវិស័យ រួមជាមួយមន្ត្រីរបស់មន្ទីរសុខាភិបាល មន្ត្រីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចូលរួម ៖ **១**-កិច្ចប្រជុំពិភាក្សាត្រៀមរៀបចំវគ្គបណ្តុះបណ្តាលស្តីពី៖ កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន ក្រោមអធិបតីភាព លោកជំ**ទាវ រ៉ែន សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ តាមប្រព័ន្ធវីដេអូហ្សូម (ZOOM)។ **២**-វគ្គបណ្តុះ |

| | |
|---|---|
| | បណ្តាល ស្តីពី ការយល់ដឹងពីមូលដ្ឋាន នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកិច្ចការពារកុមារដល់បុគ្គលិកសង្គម និងមន្ត្រីជួរមុខនៅសហគមន៍ ក្រោមអធិបតីភាព **លោក ឡៅ វេង** អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមប្រព័ន្ធវីដេអូហ្សូម (Zoom Meeting)។<br>- លោក **ស្រេង វិច្ឆិកា** នាយករងទីចាត់ការអន្តរវិស័យ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន ដើម្បីសមត្ថភាពបន្ថែម ដល់មន្ត្រីជំនាញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ លោកជំទាវ **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ នៃគ.ជ.ប.ជ នៅសាលាខេត្តបាត់ដំបង។<br>- លោកស្រី **ឡូញ ឈាង** អភិបាលរងខេត្ត បានចូលរួមប្រជុំផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នូវសៀវភៅរបាយការណ៍របស់គណៈកម្មាធិការអាស៊ាន ស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ស្តីពីអត្តសញ្ញាណស្របច្បាប់សម្រាប់ស្ត្រី និងកុមារក្នុងតំបន់អាស៊ាន តាមប្រព័ន្ធវីដេអូ ZOOM។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការយល់ដឹងពីមូលដ្ឋាន នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកិច្ចការពារកុមារដល់បុគ្គលិកសង្គម និងមន្ត្រីជួរមុខនៅសហគមន៍ ក្រោមអធិបតីភាព លោក ឡៅ វេង អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមប្រព័ន្ធ Zoom។<br>- បានចូលរួមកិច្ចប្រជុំ ពិភាក្សាត្រៀមរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន ក្រោមអធិបតីភាព លោកជំទាវ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ តាមប្រព័ន្ធ Zoom។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន ដើម្បីសមត្ថភាពបន្ថែម ដល់មន្ត្រីជំនាញ ក្រោមអធិបតីភាព លោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលាខេត្តបាត់ដំបង។<br>- បានចូលរួមបើកវគ្គបណ្តុះបណ្តាលស្តីពី ការវិភាគលើការអនុវត្តគោលនយោបាយឆ្លើយតបនឹងអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ(CEDAW)។ |
| **ខេត្តកំពង់ឆ្នាំង** | - ស្រុកលោឡៀរ បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ថ្នាក់ស្រុក ០១លើក អ្នកចូលរួម**២០**នាក់(**ស្រី១៩**នាក់)។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធ Zoom ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស អំឡុងពេលកូវីដ-១៩។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្សអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ តាមប្រព័ន្ធ Zoom ០១លើក អ្នកចូលរួម **០៦**នាក់ **ស្រី០៤**នាក់។ |
| **ខេត្តស្វាយរៀង** | - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស តាមប្រព័ន្ធ Zoom។<br>- លោកជំទាវ **ឯក សុវណ្ណភារៈ** អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយរបាយការណ៍ជាតិ ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្ស ឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ ។ |
| **ខេត្តមណ្ឌលគិរី** | - បានចូលរួមវគ្គបណ្តុះបណ្តាលលើកទី២ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងនីតិវិធីស៊ើមអង្កេត តាមប្រព័ន្ធ Zoom។ |